ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * * * * * * * * *

# យុទ្ធសាស្ត្ររេដបូកជាតិ

( សេចក្តីព្រាងចុងក្រោយ )

( ធ្វើនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៦ )

DRAFT

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ១៩៩៦ និងបានចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដូចដែលបានបង្ហាញនៅក្នុងគោលនយោបាយជាតិជាច្រើនដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម ធនធានព្រៃឈើ និងវិស័យផ្សេងទៀត រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអនុវត្តរេដបូក គឺជាការផ្តួចផ្តើមដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ និងការរួមបញ្ចូលតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព និងការបង្កើនសន្និធិកាបូនព្រៃឈើ។ រាជរដ្ឋាភិបាលកម្ពុជា មានទស្សនៈវិស័យយ៉ាងច្បាស់ថារេដបូកគឺជាយន្តការថ្នាក់ជាតិ ដែលផ្តល់ឱកាសក្នុងការគាំទ្រស្ថាប័នទទួលខុសត្រូវ រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក៏ដូចជាអ្នកពាក់ព័ន្ធរួមទាំងសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ក្នុងការខិតខំប្រឹងប្រែង ដើម្បីបន្តគ្រប់គ្រងធនធានព្រៃឈើឲ្យមានចីរភាព។

ដូច្នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានកិត្តិយស និងសោមនស្សរីករាយ សូមប្រកាសដាក់ឲ្យប្រើប្រាស់ ជាផ្លូវការនូវយុទ្ធសាស្ត្ររេដបូកជាតិ ២០១៦ - ២០២៥។ យុទ្ធសាស្ត្ររេដបូកជាតិ គឺជាការបង្ហាញនូវការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់រាជរដ្ឋភិបាល ក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាពនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនេះ។ យុទ្ធសាស្ត្ររេដបូកជាតិ គឺជាឯកសារសំខាន់មួយ ដែលបង្ហាញអំពីការអនុវត្តរេដបូកនៅថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជា។

ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិប្រកបដោយជោគជ័យ គឺអាស្រ័យលើការសហការ និងការចូលរួមពីស្ថាប័នជាតិ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ជាថ្មីម្តងទៀត ខ្ញុំសូមជម្រុញឱ្យអ្នកពាក់ព័ន្ធទាំងអស់បន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ និងចូលរួមចំណែកដល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយឧស្ម័នកាបូនក្នុងកម្រិតទាប និងបន្សាំការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

DRAFT

# អារម្ភកថា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

DRAFT

# សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។

យុទ្ធសាស្ត្ររេដបូកជាតិ ត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន និងមតិណែនាំដ៏មានតម្លៃពីក្រុមការងាររេដបូកកម្ពុជា ក្រុមបច្ចេកទេស ក្រុមប្រឹក្សាយោបល់ និងក្រុមយេនឌ័ររេដបូក។ ការចូលរួមនេះ បានធ្វើឲ្យយុទ្ធសាស្ត្ររេដបូកជាតិ មានសង្គតិភាព និងមានភាពបន្សុីគ្នានិងផែនការដែលមានស្រាប់របស់ក្រសួង ស្ថាប័ន និងវិស័យដែលពាក់ព័ន្ធ។ មតិយោបល់ដែលទទួលបានពីអ្នកពាក់ព័ន្ធទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ មានសារៈសំខាន់សម្រាប់តម្រង់ទិសយុទ្ធសាស្ត្ររេដបូកជាតិ។ បន្ថែមលើនេះ ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ក៏មានការគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញឯកទេសជាតិ និងអន្តរជាតិក្នុងការរៀបចំផងដែរ។

ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ បានធ្វើឡើងដោយមានគាំទ្រហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រួមមាន កម្មវិធីយូអិនរេដរបស់អង្គការសហប្រជាជាតិ (UN-REDD Programme) និងគម្រោងមូលនិធិភាពជាដៃគូកាបូនព្រៃឈើ (FCPF) របស់ធនាគារពិភពលោក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP ) និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត។

# មាតិកា


សារលិខិត ..... ii

អារម្ភកថា ..... iii

សេចក្តីថ្លែងអំណរគុណ ..... iv

មាតិកា ..... v

ពាក្យបំព្រួញ និងអក្សរកាត់ ..... vii

សេចក្តីសង្ខេប ..... viii

១. សេចក្តីផ្តើម ..... 1

១.១ រេដបូកកម្រិតអន្តរជាតិ ..... 1

១.២ រេដបូកនៅកម្ពុជា ..... 2

១.២.១. ការត្រៀមលក្ខណៈរេដបូកនៅកម្ពុជា ឆ្នាំ២០០៨ - ២០១៦ ..... 3

១.២.២ យុទ្ធសាស្ត្ររេដបូកជាតិ ២០១៦-២០២៥ ..... 4

២. ចក្ខុវិស័យ ..... 5

៣. បេសកកម្ម ..... 5

៤. គោលបំណង ..... 5

៥.ក្របខណ្ឌយុទ្ធសាស្ត្រ ..... 5

៥.១ វិសាលភាព និងកម្រិតអនុវត្តន៍ ..... 5

៥.២ ចំណុចវាស់វែង និងលទ្ធផល ..... 5

៥.៣ គោលការណ៍ណែនាំ ..... 6

៥.៤ ការវិភាគយុទ្ធសាស្ត្រ ..... 6

៥.៤.១ ការបន្ស៊ីជាមួយគោលបំណង និងអាទិភាពដទៃទៀតនៃការអភិវឌ្ឍជាតិ ..... 6

៥.៤.២ ទិដ្ឋភាពរួមនៃការគ្រប់គ្រងដីព្រៃ ..... 7

៥.៤.៣ បុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើនៅកម្ពុជា ..... 8

៥.៤.៤ បុព្វហេតុសំខាន់ៗដែលត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិ ..... 10

៥.៤.៥ សក្តានុពលនៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងសហប្រយោជន៍នៅក្នុងប្រទេសកម្ពុជា ..... 12

៥.៥ ទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ ..... 13


DRAFT

ទិសដៅយុទ្ធសាស្ត្រទី១៖ កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យធនធានព្រៃឈើ និងការប្រើប្រាស់ដីព្រៃឈើ ..... 13
ទិសដៅយុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការអនុវត្តសកម្មភាពគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ..... 14
ទិសដៅយុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធ ការបង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងដើម្បីអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ..... 14
៦. តំណាក់កាល ..... 15
៦.១ ដំណាក់កាលអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ..... 15
៦.២ ក្របខណ្ឌវ៉ស័រ (Warsaw) សម្រាប់រេដបូក ..... 17
៦.២.១ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក (SIS) ..... 18
៦.២.២ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS) ..... 20
៦.២.៣ កម្រិតយោងព្រៃឈើ (FREL/FRL) ..... 23
៦.៣ ការរៀបចំយន្តការ និងការសម្របសម្រួល ..... 25
៦.៣.១ ការរៀបចំរចនាសម្ព័ន្ធដែលមានស្រាប់ សម្រាប់ពិនិត្យមើលការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ..... 25
៦.៣.២ ការរៀបចំរចនាសម្ព័ន្ធសម្រាប់តាមដានត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ..... 26
៧. ធនធានហិរញ្ញវត្ថុ ..... 27
៧.១ ប្រភពហិរញ្ញប្បទាន ..... 28
៧.២ អភិក្រមផ្អែកលើមូលនិធិ (Fund Based Approach) ..... 28
៧.៣ គោលការណ៍ ..... 28
៧.៤ ការបង្កើតភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក ..... 29
៨. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ..... 30
៨.១ គោលការណ៍ ..... 31
៨.២ អភិក្រម ..... 31
៨.៣ ការគ្រប់គ្រង និងការចាត់ចែងរចនាសម្ព័ន្ធសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ..... 32
៩. សេចក្តីសន្និដ្ឋាន ..... 32

DRAFT

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| BUR | Biannual Update Report | របាយការណ៍បច្ចុប្បន្នភាពរៀងរាល់២ឆ្នាំម្តង |
| COP | Conference of the Parties | សន្និសីទនៃបណ្តាភាគី |
| ELCs | Economic Land Concessions | សម្បទានដីសេដ្ឋកិច្ច |
| ER | Emissions Reduction | ការកាត់បន្ថយការបំភាយឧស្ម័ន |
| FA | Forestry Administration | រដ្ឋបាលព្រៃឈើ |
| FCPF | Forest Carbon Partnership Facility | មូលនិធិភាពជាដៃគូកាបូនព្រៃឈើ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| GHG | Greenhouse Gas | ឧស្ម័នផ្ទះកញ្ចក់ |
| GRM | Grievance Redress Mechanism | យន្តការដោះស្រាយបណ្តឹងសារទុក្ខ |
| IPCC | Intergovernmental Panel on Climate Change | គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MRV | Measurement, Reporting and Verification | ការពិនិត្យតាមដាន ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ |
| M&E | Monitoring and Evaluation | ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ |
| NC | National Communication | របាយការណ៍ជាតិ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព |
| NFI | National Forest Inventory | សារពើភណ្ឌព្រៃឈើជាតិ |
| NFMS | National Forest Monitoring System | ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ |
| NFP | National Forest Programme | កម្មវិធីព្រៃឈើជាតិ |
| NGOs | Non-Governmental Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| NPASMP | National Protected Areas Strategic Management Plan | ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| NRC | National REDD+ Committee | គណៈកម្មាធិការរេដបូកជាតិ |
| NRS | National REDD+ Strategy | យុទ្ធសាស្ត្ររេដបូកជាតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PLRs | Policies, Laws and Regulations | គោលនយោបាយ ច្បាប់ និងបទបញ្ញត្តិ |
| REDD+ | Reducing Emissions from Deforestation and forest Degradation, conservation of forest carbon stocks, sustainable management of forests, and enhancement of forest carbon stocks | កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ ការអភិរក្សកាបូនស្តុកព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព និងការបង្កើនសន្និធិកាបូនព្រៃឈើ |

DRAFT

# សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាគាំទ្រដល់ការរៀបចំ និងការអនុវត្តយន្តការរេដបូក ហើយបានចាត់ទុកយន្តការនេះជាជម្រើសមួយ ក្នុងការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីវិស័យព្រៃឈើ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ការផ្លាស់ប្តូរទៅរកការអភិវឌ្ឍដោយចីរភាព។ គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការអភិវឌ្ឍជាតិដែលមានជាធរមាននៅកម្ពុជា ក៏បានសុខដុមកម្មបញ្ចូលរេដបូក ជាផ្នែកមួយនៃរបៀបវារៈជាយុទ្ធសាស្ត្រផងដែរ។ យុទ្ធសាស្ត្ររេដបូក នឹងអនុលោមតាមសេចក្តីសម្រេចរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ ការអនុវត្តរេដបូកនៅកម្ពុជា ចែកចេញជាបីដំណាក់កាលជាបន្តបន្ទាប់រួមមាន ដំណាក់កាលត្រៀមលក្ខណៈ ដំណាក់កាលអនុវត្ត និងដំណាក់កាលទូទាត់ផ្អែកតាមលទ្ធផល (RBP) នៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីវិស័យព្រៃឈើ និងការប្រើប្រាស់ដី។ បច្ចុប្បន្ន កម្ពុជាកំពុងអនុវត្តបញ្ចប់ដំណាក់កាលនៃការត្រៀម និងគ្រោងឈានបន្តទៅ ដំណាក់កាលអនុវត្តយុទ្ធសាស្ត្ររេដបូក ដែលនឹងចាប់ផ្តើមពីឆ្នាំ២០១៧តទៅ។ ដោយផ្អែកតាមក្របខណ្ឌរេដបូកនៃទីក្រុងវ៉ស្ស័រ (Warsaw) កម្ពុជាបានរៀបចំធាតុផ្សំដែលពាក់ព័ន្ធចំនួនបួន៖ (១)យុទ្ធសាស្ត្ររេដបូកជាតិ (NRS) (២)ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ(NFMS) (៣)ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក(SIS) និង (៤) កម្រិតយោងព្រៃឈើ (FRL) ។

ផ្អែកតាមគោលការណ៍ណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការរៀបចំយុទ្ធសាស្ត្រជាតិ យុទ្ធសាស្ត្ររេដបូកជាតិ ត្រូវបានរៀបចំឡើង ដោយអនុលោមតាមគោលនយោបាយ និងអាទិភាពជាតិទាំងពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងបានបង្កើតចក្ខុវិស័យ បេសកកម្ម គោលបំណង ក្របខណ្ឌយុទ្ធសាស្ត្រដែលផ្សំដោយទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ ការកំណត់សកម្មភាព ការរៀបចំក្របខណ្ឌរចនាសម្ព័ន្ធ និងយន្តការអនុវត្ត ការវិភាគធនធានហិរញ្ញវត្ថុ និងការរៀបចំក្របខណ្ឌការងារសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ចក្ខុវិស័យ បេសកកម្ម និងគោលបំណងនៃយុទ្ធសាស្ត្ររេដបូកជាតិត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគសមត្ថភាពស្ថាប័ន បទពិសោធន៍ក្នុងការគ្រប់គ្រងដីព្រៃឈើ និងយុទ្ធសាស្ត្រឆ្លើយតបតម្រូវការយេនឌ័រ ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ។

**ចក្ខុវិស័យ៖** យុទ្ធសាស្ត្ររេដបូកជាតិរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុជាតិ និងពិភពលោកតាមរយៈការធ្វើឲ្យប្រសើរឡើងការងារគ្រប់គ្រងធនធាននិងដីព្រៃឈើ និងការអភិរក្សជីវចម្រុះប្រកបដោយចីរភាព។

**បេសកកម្ម៖** កែលម្អមុខងារនិងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់និងបទប្បញ្ញត្តិនានាដែលមានជាធរមាន ដើម្បីសម្រេចបាននូវការធ្វើឲ្យប្រសើរឡើង ការងារគ្រប់គ្រងធនធាននិងដីព្រៃឈើ និងការអភិរក្សជីវចម្រុះប្រកបដោយចីរភាព។

**គោលបំណង៖** កាត់បន្ថយការបាត់បង់និងការរេចរិលព្រៃឈើតាមរយៈការលើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍព្រៃឈើ ការបង្កើនសន្និធិកាបូន និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

ជាដំបូង យុទ្ធសាស្ត្ររេដបូកជាតិ ផ្តោតលើ ការដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងកសាងសមត្ថភាពជាបណ្តើរៗ ដើម្បីដោះស្រាយបុព្វហេតុនៃការរេចរិលព្រៃឈើ។ បន្ទាប់មកកម្ពុជានឹងអនុវត្តរេដបូកកម្រិតជាតិ តាមយន្តការនៃការទូទាត់ផ្អែកលើលទ្ធផល ក្រោមអនុសញ្ញា UNFCCC។

ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលបំណងទាំងនេះ យុទ្ធសាស្ត្ររេដបូកជាតិបានកំណត់ទិសដៅយុទ្ធសាស្ត្រចំនួន៣ និងយុទ្ធសាស្ត្រចំនួន២០ រួមមាន៖

- កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យធនធានព្រៃឈើនិងការប្រើប្រាស់ដីព្រៃឈើ

DRAFT

- លើកកម្ពស់ការអនុវត្តសកម្មភាពគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តភាព និងអភិរក្សជីវចម្រុះដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ការបង្កើនសមត្ថភាព ចំណេះដឹងនិងការយល់ដឹងដើម្បីអនុវត្តន៍យុទ្ធសាស្ត្ររេដបូកជាតិ។

ដោយអនុវត្តន៍តាមវិធីសាស្ត្រជាជំហានៗ យុទ្ធសាស្ត្ររេដបូកជាតិ បានកំណត់នូវយុទ្ធសាស្ត្រ និងសកម្មភាពមួយចំនួនសម្រាប់ការអនុវត្ត ជាពីរដំណាក់កាលៈ តំណាក់កាលទី១ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០២០) ដំណាក់កាលនេះ ត្រូវរៀបចំផែនការសកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០១៧-២០២០ដោយរួមបញ្ចូលផែនការសកម្មភាពជាក់លាក់សម្រាប់ការប្រមូលផ្តុំនិងចែករំលែកចំណេះដឹង សម្របសម្រួលការអនុវត្តមុខងារ ការរៀបចំរចនាសម្ព័ន្ធ និងហិរញ្ញវត្ថុ សម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិនឹងត្រូវរៀបចំឡើងផងដែរ រួមជាមួយការបង្កើតក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្របព្រៃឈើថ្នាក់ជាតិ និងផ្តោតសំខាន់លើការអនុវត្តផែនការសកម្មភាពរេដបូក ដើម្បីធានាថាកម្ពុជានឹងអាចស្នើសុំឲ្យមានការទូទាត់ដោយផ្អែកតាមលទ្ធផល សម្រាប់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។ សូមកត់សម្គាល់ថា គោលនយោបាយ និងវិធានការរេដបូក ដែលបានអនុវត្តនៅក្នុងដំណាក់កាលនេះ មានគោលដៅដោះស្រាយទាំងបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ប៉ុន្តែមានតែគោលនយោបាយ និងវិធានការរេដបូកដែលដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើតែប៉ុណ្ណោះ នឹងត្រូវបានវាយតម្លៃសម្រាប់ការទូទាត់ផ្អែកតាមលទ្ធផល ដោយសារតែក្របខណ្ឌបច្ចេកទេស និងលទ្ធភាពរបស់ប្រទេសកម្ពុជា នៅក្នុងដំណាក់កាលដំបូងនៃការរៀបចំកម្រិតយោងព្រៃឈើ នៅមានកម្រិតនៅឡើយ។ គោលនយោបាយ និងវិធានការរេដបូក ដ៏ទៃទៀតនឹងត្រូវអនុវត្ត ដោយផ្អែកតាមមូលហេតុចំនួនពីរដែលមានទំនាក់ទំនងគ្នាគឺ (១) បង្កើតមេរៀនស្តីពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ក្នុងការដោះស្រាយបុព្វហេតុនៃការរេចរិលព្រៃឈើ និងបុព្វហេតុដែលពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការអភិរក្ស និងការបង្កើនសន្និធិកាបូនព្រៃឈើ និង(២)ប្រើប្រាស់មេរៀនទាំងនេះ ដើម្បីកែលម្អសមត្ថភាពបច្ចេកទេស និងវិសាលភាពកម្រិតយោងព្រៃឈើបច្ចុប្បន្ន។ តំណាក់កាទី២ (ឆ្នាំ២០២១ ដល់២០២៥) នៅដើមឆ្នាំ២០២១ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ កម្រិតយោងព្រៃឈើ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក និងទិន្នន័យដទៃទៀតនឹងត្រូវបានកែលម្អ ដូច្នេះយុទ្ធសាស្ត្ររេដបូកជាតិនឹងត្រូវធ្វើបច្ចុប្បន្នភាព និងដាក់រួមបញ្ចូលការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ដែលដោះស្រាយបុព្វហេតុដទៃទៀតនៃការបាត់បង់ និងការរេចរិលព្រៃឈើ។ ជាការសំខាន់ គោលនយោបាយ និងវិធានការរេដបូក ដែលបានអនុវត្តពីឆ្នាំ២០១៦ ដល់២០២០ ត្រូវតាមដានត្រួតពិនិត្យយ៉ាងហ្មត់ចត់លើប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ តាមរយៈយន្តការផ្តល់យោបល់ឆ្លើយតបនៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក ក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ វិធីសាស្ត្រ គោលនយោបាយ និងវិធានការរេដបូក នៅទីវាលនឹងត្រូវកែលម្អជាបន្តបន្ទាប់ និងអភិវឌ្ឍបន្ថែមទៀត ទៅតាមការចាំបាច់នៅពេលដែលទទួលបានមេរៀន និងបទពិសោធន៍ពីការអនុវត្ត។

ការរៀបចំរចនាសម្ព័ន្ធសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ទទួលស្គាល់តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នផ្សេងគ្នានៅក្នុងរាជរដ្ឋាភិបាល ដែលមានសមត្ថកិច្ចគ្រប់គ្រងធនធានព្រៃឈើជាតិ។ ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិរំពឹងថា នឹងគោរពទៅតាមដែនសមត្ថកិច្ចរបស់ស្ថាប័ននីមួយៗរបស់រាជរដ្ឋាភិបាល ដែលមានសមត្ថកិច្ចផ្សេងៗគ្នា ដែលបានរួមចំណែករៀបចំផែនការសកម្មភាពរេដបូក ក្នុងដែនសមត្ថកិច្ចដីព្រៃឈើខុសៗគ្នា ដោយផ្អែកលើច្បាប់ និងគោលនយោបាយ ដែលមានជាធរមាន។

ពីឆ្នាំ២០១៦ ដល់២០២០ មុខងារ សម្របសម្រួលរបស់ក្រុមការងាររេដបូកជាតិ លេខាធិការដ្ឋានរេដបូក ក្រុមការងារបច្ចេកទេសរេដបូក ក្រុមប្រឹក្សាយោបល់រេដបូក និងក្រុមយេនឌ័ររេដបូកនឹងនៅបន្តជាធរមាន។ ដោយឡែក ការតាមដាន

DRAFT

ត្រួតពិនិត្យ ការទទួលខុសត្រូវសម្របសម្រួលការអនុវត្តនៅក្នុងដំណាក់កាលទូទាត់ដោយផ្អែកលើលទ្ធផល ចាប់ពីឆ្នាំ២០២១ ទៅ មុខងារ និងអំណាចរបស់ក្រុមការងាររេដបូកនិងលេខាធិការដ្ឋានរេដបូក នឹងត្រូវកែលម្អឲ្យកាន់តែប្រសើរឡើង។ មុខងារសំខាន់ៗ របស់ស្ថាប័នតាមដានត្រួតពិនិត្យ លើការអនុវត្តនៅក្នុងដំណាក់កាលរួមមាន ៖

- ដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយ និងវិធានការរេដបូកនៅថ្នាក់ជាតិ
- ត្រួតពិនិត្យ និងបង្កើនការកែលម្អអភិបាលកិច្ចធនធានព្រៃឈើ ដើម្បីកាត់បន្ថយអត្រានៃការបាត់បង់ និងការរេចរិលព្រៃឈើ
- ធានាឲ្យមានការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពក្នុងការផ្តល់មូលនិធិ និងការវិភាជន៍ថវិកាលើកទឹកចិត្តស្ថាប័នអនុវត្តអោយបានត្រឹមត្រូវ ក្នុងការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។

ជាការចាំបាច់ នីតិវិធីត្រូវមានតម្លាភាពប្រកបដោយបរិយាកាសគាំទ្រ ដើម្បីធានាគណនេយ្យភាពសាធារណៈ ទិន្នន័យ និងផែនទីត្រូវដាក់បញ្ចូលគ្នា ហើយត្រូវធានាឲ្យមានប្រសិទ្ធភាព សមភាព និងអាចសម្របសម្រួលប្រើប្រាស់បានតាមសេចក្តីត្រូវការរបស់វិស័យ និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនៅគ្រប់កម្រិត។ កំណែទម្រង់ទាំងនេះ ត្រូវការជាចាំបាច់នូវការប្តេជ្ញាចិត្តចំពោះផលប្រយោជន៍សាធារណៈ និងអន្តរវិស័យដូចជាយេនឌ័រនិងរេដបូក និងឆ្លើយតបចំពោះគ្រប់ភាគីពាក់ព័ន្ធ។ ដូច្នេះកំណែទម្រង់នេះត្រូវស្វែងរកគ្រប់វិធីសម្រាប់លើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរពីរបៀបរបបធ្វើការតាមទម្លាប់ ដើម្បីឲ្យកម្ពុជាអាចផ្លាស់ប្តូរទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព និងយកចិត្តទុកដាក់ដល់ការចូលរួមប្រកបដោយជោគជ័យពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកាត់បន្ថយការបាត់បង់ និងការរេចរិលព្រៃឈើ ដែលជាគោលដៅចុងក្រោយនៃយុទ្ធសាស្ត្ររេដបូកជាតិ ។

DRAFT

## ១. សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលគាំទ្រដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោកក្នុងការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ ប្រទេសកម្ពុជា មានគម្របព្រៃឈើច្រើននៅអាស៊ីអាគ្នេយ៍ ហើយក៏ជាប្រទេសដែលបានទទួលស្គាល់ផងដែរថា ការបាត់បង់ និងការរេចរិលព្រៃឈើ គឺជាប្រភពដ៏សំខាន់នៃការបំភាយឧស្ម័នផ្ទះកញ្ចក់។ ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញា UNFCCC ប្រទេសកម្ពុជាបានផ្ដល់ការគាំទ្រសេចក្ដីសម្រេចចិត្ត និងសកម្មភាព ដែលទាក់ទងនឹងការកាត់បន្ថយការប្រែប្រួលអាសធាតុតាមរយៈការធ្វើឲ្យប្រសើរឡើងការងារគ្រប់គ្រងធនធាននិងដីព្រៃឈើ និងការអភិរក្សជីវចម្រុះប្រកបដោយចីរភាព។

ប្រទេសកម្ពុជាបានគាំទ្រយន្តការរេដបូក ដែលបានផ្ដួចផ្ដើមដោយសន្និសិទ្ធបណ្ដាភាគី (COP) នៃអនុសញ្ញា UNFCCC ទីក្រុងបាលី ឆ្នាំ២០០៧ ដែលនេះជាគំនិតផ្ដួចផ្ដើមឲ្យមានគោលនយោបាយពិភពលោក ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងការរេចរិលព្រៃឈើ និងតួនាទីនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការអភិរក្ស និងការបង្កើនសន្និធិកាបូនព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

កម្ពុជាជាប្រទេសមួយនៅក្នុងចំណោមប្រទេសជាច្រើន ដែលបានចាប់ផ្ដើមអនុវត្តរេដបូក។ នៅឆ្នាំ២០០៨ គម្រោងសាកល្បងរេដបូកចំនួនពីរបានបង្កើតឡើង ហើយនៅឆ្នាំ២០១០ ផែនទីបង្ហាញផ្លូវរេដបូកជាតិក៏បានចាប់ផ្ដើមអនុវត្ត។ ការត្រៀមលក្ខណៈរេដបូកនៅកម្ពុជា បានចាប់ផ្ដើមអនុវត្តនៅឆ្នាំ២០១២ ស្របនឹងការបង្កើតឡើងកម្មវិធីរេដបូកជាតិ និងការរៀបចំរចនាសម្ព័ន្ធក្រុមការងាររេដបូកជាតិ លេខាធិការដ្ឋានរេដបូក និងការរៀបចំឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ការកសាងសមត្ថភាព និងការបង្កើនការយល់ដឹង នៅតែបន្តជាសមាសធាតុដ៏រឹងមាំសម្រាប់រេដបូកនៅកម្ពុជា ដែលបច្ចុប្បន្នទទួលបានការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាពីដៃគូរអភិវឌ្ឍន៍នានា។

### ១.១ រេដបូកកម្រិតអន្តរជាតិ

ចាប់ពីឆ្នាំ២០០៥មក ប្រទេសជាភាគីនៅក្រោមអនុសញ្ញា UNFCCC បាននឹងកំពុងធ្វើការចរចាយ៉ាងសកម្ម ដើម្បីបង្កើតកិច្ចផ្ដួចផ្ដើមគោលនយោបាយ ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ដែលនឹងរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈសកម្មភាពនៅក្នុងវិស័យព្រៃឈើ។ កិច្ចផ្ដួចផ្ដើមនេះត្រូវបានគេស្គាល់ថា **ជាការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងការរេចរិលព្រៃឈើ (រេដ)** និងបូក (+) **សំដៅលើ**តួនាទីនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ការអភិរក្ស និងការបង្កើនសន្និធិកាបូនព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ តាមរយៈកិច្ចព្រមព្រៀងក្រុងកាន់គុណ នៅក្រោមអនុសញ្ញា UNFCCC (សេចក្ដីសម្រេចលេខ 1/CP.16) ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានលើកទឹកចិត្តឲ្យចូលរួមចំណែកនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ដោយអនុវត្តសកម្មភាពទៅតាមស្ថានភាពសមស្រប យោងតាមសមត្ថភាព និងកាលៈទេសៈរបស់ប្រទេសជាភាគី។ សកម្មភាពទាំងនោះរួមមានការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងការរេចរិលព្រៃឈើ ការអភិរក្សសន្និធិកាបូនព្រៃឈើ ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព និងការបង្កើនសន្និធិកាបូនព្រៃឈើ ។

អនុសញ្ញា UNFCCC ក៏បានបង្កើតដំណើរការ វិធាន និងបែបបទសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផល ពីការអនុវត្តគោលនយោបាយ និងវិធានការរេដបូករបស់ខ្លួន ជាពិសេសនៅពេលថ្មីៗនេះ ក្របខណ្ឌវ៉ស៊ែរសម្រាប់រេដបូក បានរំលឹកឡើងថា ប្រទេសកំពុងអភិវឌ្ឍន៍ដែលអនុវត្តសកម្មភាពនានា ដូចមានយោងនៅក្នុងកិច្ចព្រមព្រៀងក្រុងកាន់គុណ ដើម្បីអាចទទួលបានការទូទាត់ផ្អែកលើលទ្ធផល ចាំបាច់ត្រូវវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់

DRAFT

សកម្មភាពទាំងនោះដោយប្រុងប្រយ័ត្ន។ ម៉្យាងទៀត ផ្អែកលើកិច្ចព្រមព្រៀងក្រុងកាន់គុណក្របខណ្ឌក្រុងវ៉ស៊ែរបានចែងថា មុននឹងបានទទួលការទូទាត់ផ្អែកលើលទ្ធផល ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវរៀបចំធាតុផ្សំទាំងបួនឲ្យបានស្រេច (**ដូចបង្ហាញជូនក្នុងរូបទី ១**) និងត្រូវធានាថា សេចក្តីសង្ខេបអំពីរបៀបនៃការដោះស្រាយ និងការគោរពតាមប្រព័ន្ធធានាសុវត្ថិភាពរេដបូកក្រុងកាន់គុណ ត្រូវបានផ្តល់តាមរយៈមណ្ឌលព័ត៌មានអនុសញ្ញា UNFCCC សម្រាប់រេដបូក។ នៅពេលដែលធាតុផ្សំទាំងបួននេះត្រូវបានបង្កើតរួចហើយ ដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផលនៅក្រោមអនុសញ្ញា UNFCCC ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវអនុវត្តតាមវិធីរាយការណ៍ផ្សេងគ្នាចំនួនពីរ៖ វិធីទី១ ការវាយតម្លៃបច្ចេកទេសលើកម្រិតយោងព្រៃឈើ ដែលបានរៀបចំឡើងសម្រាប់ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ការបំភាយដែលទាក់ទងនឹងសកម្មភាពមនុស្សក្នុងវិស័យព្រៃឈើ ការស្រូបយកសន្និធិកាបូនព្រៃឈើ និងបម្រែបម្រួលសន្និធិកាបូនព្រៃឈើ និងទំហំដីព្រៃឈើដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។ វិធីទី២ ការធ្វើរបាយការណ៍លទ្ធផលនៃការបន្ធូរបន្ថយ ឬ ការកាត់បន្ថយតាមរយៈការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ (NC) និងឧបសម្ព័ន្ធបច្ចេកទេសនៃរបាយការណ៍បច្ចុប្បន្នភាពរយៈពេលពីរឆ្នាំម្តង (BUR)។ ជាងនេះទៀត ប្រទេសនីមួយៗត្រូវដាក់ជូនសេចក្តីសង្ខេបព័ត៌មានស្តីពីរបៀបដែលប្រព័ន្ធធានាសុវត្ថិភាពរេដបូកបានដោះស្រាយ និងគោរព នៅគ្រប់ពេលនៃការអនុវត្តសកម្មភាពរេដបូក ដែលមានទំនាក់ទំនងទៅនឹងយុទ្ធសាស្ត្រ ឬ ផែនការសកម្មភាពរេដបូកជាតិ ។




រូបភាពទី១៖ ក្របខណ្ឌវ៉ស៊ែរសម្រាប់រេដបូក

## ១.២ រេដបូកនៅកម្ពុជា

ប្រទេសកម្ពុជាបានប្រកាសនៅក្នុងសន្និសីទបណ្តាភាគី នៃអនុសញ្ញា UNFCCC នាឆ្នាំ ២០០៧ ដែលបានប្រព្រឹត្តឡើងក្នុងប្រទេសឥណ្ឌូនេស៊ីថា "រាជរដ្ឋាភិបាលកម្ពុជាគាំទ្រយ៉ាងខ្លាំង ចំពោះការរួមបញ្ចូលការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការអភិរក្សព្រៃឈើ និងការបញ្ចៀសការបាត់បង់ព្រៃឈើនៅក្នុងក្របខណ្ឌក្រោយអាណត្តិនៃពិធីសារក្យូតូ។ ក្នុងដំណាក់កាលត្រៀមលក្ខណៈរេដបូក កម្ពុជាបានធ្វើឲ្យមានវឌ្ឍនភាពជាច្រើន។ សូចនាករនៃវឌ្ឍនភាពនេះរួមមាន ការផលិតឯកសារបច្ចេកទេស និងការសិក្សា ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការរៀបចំធាតុផ្សំទាំងបួន។ ឯកសារបច្ចេកទេស និងការសិក្សា មាននៅក្នុងវេបសាយរេដបូកកម្ពុជា៖ (http://www.cambodia-redd.org/category/document-centre/technical-reports/redd-cambodia-prorgamme)

- ការវិភាគថ្លៃចំណាយ និងផលចំណេញពីការអនុវត្តរេដបូក
- ប្រព័ន្ធចំណាត់ថ្នាក់គម្របដី និងព្រៃឈើ

DRAFT

- អនុសាសន៍ស្តីពីប្រព័ន្ធចំណាត់ថ្នាក់ដីធ្លី និងព្រៃឈើ
- កម្រងទិន្នន័យរូបភាពផ្កាយរណប និងផែនទីសន្ទស្សន៍សម្រាប់ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ
- ការពិនិត្យឡើងវិញ និងវិធីសាស្ត្រសម្រាប់ការបង្កើតប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក
- សមីការវិមាត្រសាស្ត្រ(អាឡូមេទ្រិក)រវាងមាឌដើមឈើ និងជីវម៉ាស់
- ការបង្កើតរចនាសម្ព័ន្ធជាតិគ្រប់គ្រងមូលនិធិរេដបូកប្រកបដោយតម្លាភាព និងគណនេយ្យភាព
- វិធីសាស្ត្រដើម្បីបង្កើតប្រព័ន្ធវិភាជន៍ថវិកាលើកទឹកចិត្ត និងការបែងចែកផលប្រយោជន៍រេដបូក
- ឆ្ពោះទៅបង្កើតយន្តការដោះស្រាយទំនាស់រេដបូក។

នាទសវត្សរ៍ខាងមុខ គោលនយោបាយ ផែនការ កម្មវិធី និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងដាក់បញ្ចូលរេដបូកជាផ្នែកមួយនៃរបៀបវារៈជាយុទ្ធសាស្ត្រ និងផែនការការងារ។ ឧទាហរណ៍ ទិសដៅយុទ្ធសាស្ត្រទីបីនៃផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា(ឆ្នាំ២០១៤-២០២៣) បានចាត់ទុករេដបូកជាយន្តការមួយដើម្បីធានាថា ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ មានភាពធន់ចំពោះអាកាសធាតុ។ នៅក្នុងឯកសារជាតិទាំងនេះ រាជរដ្ឋាភិបាលបានចាត់ទុករេដបូកជាមធ្យោបាយមួយរបស់កម្ពុជាក្នុងនាមជាហត្ថលេខីនៃអនុសញ្ញា UNFCCC ក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុពិភពលោក ដែលអាចសម្រេចគោលបំណងចុងក្រោយនៃអនុសញ្ញា UNFCCC និងបំពេញបាននូវការប្តេជ្ញានានាក្រោមអនុសញ្ញានេះ។ ទន្ទឹមនឹងនេះ រេដបូកត្រូវបានចាត់ទុកជាយន្តការដើម្បីកៀរគរការគាំទ្រហិរញ្ញវត្ថុបន្ថែមសម្រាប់រាជរដ្ឋាភិបាល ដើម្បីរៀបចំ និងពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិដែលទាក់ទងនឹងការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តភាព និងការកាត់បន្ថយភាពក្រីក្រ។

### ១.២.១. ការត្រៀមលក្ខណៈរេដបូកនៅកម្ពុជា ឆ្នាំ២០០៨ - ២០១៦

ក្នុងរយៈពេលពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៦ កម្មវិធីរេដបូកជាតិបានសម្រេចគោលដៅ និងទទួលបានមេរៀនសំខាន់ៗជាច្រើន។ គោលដៅ និងមេរៀនទាំងនេះរួមមាន ការយល់ដឹងជារួមថារេដបូកត្រូវតែបញ្ជ្រាបនៅក្នុងគោលនយោបាយដែលមានជាធរមាន និងផែនការគោលនយោបាយជាតិ ក្របខណ្ឌការងារ និងផែនការនានាទាក់ទងទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព ការបន្សាំកសិកម្ម ការអភិរក្ស និងការអភិវឌ្ឍដែលមានការបំភាយកាបូនតិច។ ដើម្បីឲ្យការអនុវត្តរេដបូកអាចមានលទ្ធភាពដោះស្រាយផលប៉ះពាល់ដែលបណ្តាលមកពីការអភិវឌ្ឍទាំងមានការអនុញ្ញាត និងគ្មានការអនុញ្ញាត ទៅលើធនធានព្រៃឈើទទួលបានជោគជ័យ លុះត្រាតែមានការសម្របសម្រួលល្អរវាងអន្តរក្រសួង និងភ្នាក់ងារមានសមត្ថកិច្ច។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការសំខាន់ៗ ដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងការកែលម្អយន្តការសម្របសម្រួលដែលនឹងមានផលប៉ះពាល់ជាវិជ្ជមានដល់ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តភាព។ ផែនការយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ (២០១៤-២០២៣) ត្រូវបានអនុម័ត ហើយកំពុងត្រូវបានបញ្ជ្រាបទៅក្នុងដំណើរការកសាងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាប្រឈមនានាទាក់ទងទៅនឹងការអភិវឌ្ឍដោយចីរភាពថ្នាក់ជាតិ។ រាជរដ្ឋាភិបាលទទួលស្គាល់ថាការអភិវឌ្ឍធនធនព្រៃឈើដោយចីរភាព នឹងរួមចំណែកយ៉ាងសំខាន់ដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានក្នុងការទទួលបាននូវសហប្រយោជន៍ និងកសាងភាពបន្សាំ នឹងការប្រែប្រួលអាកាសធាតុ និងហេតុការណ៍ផ្សេងៗទៀត ។

DRAFT

### ១.២.២ យុទ្ធសាស្ត្ររេដបូកជាតិ ២០១៦-២០២៥

យុទ្ធសាស្ត្ររេដបូកជាតិសម្រាប់រយៈពេលពីឆ្នាំ២០១៧-២០២៥ ត្រូវបានចាប់ផ្តើមរៀបចំឡើងនៅឆ្នាំ២០១៤។ យុទ្ធសាស្ត្ររេដបូកជាតិ ក៏បានអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងកាន់គុណ ក្របខណ្ឌវ៉ស័រសម្រាប់រេដបូក កិច្ចព្រមព្រៀងទីក្រុងប៉ារីស និងគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា។ កម្ពុជាបានពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ បានរៀបចំបញ្ចប់នូវកម្រិតយោងព្រៃឈើ បានវិភាគ និងបង្កើនការយល់ដឹងពីប្រព័ន្ធធានាសុវត្ថិភាពរេដបូក រួមទាំងយន្តការដោះស្រាយវិវាទ។ ក្របខណ្ឌរចនាសម្ព័ន្ធរេដបូក នឹងបង្កលក្ខណៈងាយស្រួលក្នុងការរាយការណ៍ពីការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់ដី ការផ្លាស់ប្តូរការប្រើប្រាស់ដីនិងព្រៃឈើ និងផ្តល់ឯកសារយោងរបាយការណ៍បច្ចេកទេសបច្ចុប្បន្នភាពពីរឆ្នាំម្តងដើម្បីដាក់ជូន UNFCCC ដែលជាផ្នែកមួយនៃដំណើរការស្នើសុំការទូទាត់ផ្អែកលើលទ្ធផលសម្រាប់សកម្មភាពរេដបូក។ ក្របខណ្ឌពេលវេលាសម្រាប់កសាងកម្រិតយោងព្រៃឈើ គឺពីចន្លោះឆ្នាំ២០០៦-២០១០ ឆ្នាំ២០១០-២០១៤ និងឆ្នាំ២០១៤-២០១៦។

ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិបានប្រព្រឹត្តទៅតាមដំណើរការដែលមានការពិគ្រោះយោបល់ពេញលេញ ពីគ្រប់ភាគីពាក់ព័ន្ធ។ ផែនទីបង្ហាញផ្លូវសម្រាប់ការពិគ្រោះយោបល់ត្រូវបានរៀបចំ ហើយកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិច្រើនលើកត្រូវបានរៀបចំ និងប្រព្រឹត្តទៅ ដើម្បីធានាថាគ្រប់ភាគីពាក់ព័ន្ធទាំងអស់មកពីសហគមន៍មូលដ្ឋាន ស្ត្រីក្រុមអ្នកប្រើប្រាស់ព្រៃឈើ អង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងពាក់ព័ន្ធ ត្រូវបានផ្តល់ឱកាសពេញលេញក្នុងការរួមចំណែកផ្តល់យោបល់ និងធាតុចូលគ្រប់គ្រាន់ដល់ការរៀបចំយុទ្ធសាស្ត្រ។ ក្រុមប្រឹក្សាយោបល់ដែលមានតំណាងមកពីសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ ជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិលថ្នាក់ខេត្ត និងគ្រឹះស្ថានសិក្សា បានចូលរួមយ៉ាងសកម្មជាមួយនឹងដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ។ ថែមពីនេះ ក្រុមយេនឌ័ររេដបូកក៏ត្រូវបានបង្កើតឡើង ដើម្បីចូលរួមពិគ្រោះយោបល់ និងផ្តល់ធាតុចូលដល់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ ទៅកាន់សហគមន៍អន្តរជាតិនៅក្នុងសន្និសីទបណ្តាភាគីលើកទី២១នៅទីក្រុងប៉ារីស។ យុទ្ធសាស្ត្ររេដបូកនេះបង្ហាញច្បាស់ពី ចក្ខុវិស័យ បេសកកម្ម និងគោលបំណងកំណត់ពីនិន្នាការ និងបុព្វហេតុនៃការបាត់បង់ព្រៃឈើ ព្រមទាំងលើកស្នើឡើងនូវទិសដៅយុទ្ធសាស្ត្រ គោលនយោបាយ និងវិធានការរេដបូក ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ និងរេចរិលព្រៃឈើ។ ដើម្បីសម្រេចបានផលប៉ះពាល់ជាវិជ្ជមានពីការអនុវត្តគោលនយោបាយ និងវិធានការរេដបូកដ៏មានប្រសិទ្ធភាព ត្រូវមានការសម្របសម្រួលអន្តរវិស័យ មានធនធានបច្ចេកទេស ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្ត។ ដូច្នេះ ក្នុងពេលវេលាជាក់លាក់មួយ យើងនឹងអាចសម្រេចលទ្ធផលក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក៏ដូចជាការរួមចំណែកដល់ការអភិវឌ្ឍ ការពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តភាព។ ទាំងនេះ គឺជាការគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការប្រែប្រួលអាកាសធាតុទាំងនៅកម្រិតជាតិ និងពិភពលោកតាមរយៈកែលម្អការគ្រប់គ្រងធនធានព្រៃឈើរបស់ខ្លួន។

## ២. ចក្ខុវិស័យ

យុទ្ធសាស្ត្ររេដបូកជាតិរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុជាតិ និងពិភពលោកតាមរយៈការធ្វើឲ្យប្រសើរឡើងការងារគ្រប់គ្រងធនធាននិងដីព្រៃឈើ និងការអភិរក្សជីវចម្រុះដោយចីរភាព។

## ៣. បេសកកម្ម

កែលម្អមុខងារ និងសមត្ថភាពរបស់ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានជាធរមាន ដើម្បីសម្រេចបាននូវការធ្វើឲ្យប្រសើរឡើងការងារគ្រប់គ្រងធនធាននិងដីព្រៃឈើ និងការអភិរក្សជីវចម្រុះដោយចីរភាព។

## ៤. គោលបំណង

កាត់បន្ថយការបាត់បង់និងការរេចរិលព្រៃឈើតាមរយៈការលើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍព្រៃឈើ ការបង្កើនសន្និធិកាបូន និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

## ៥.ក្របខណ្ឌយុទ្ធសាស្ត្រ

ក្របខណ្ឌយុទ្ធសាស្ត្ររេដបូកជាតិឆ្នាំ២០១៧-២០២៥ ផ្អែកលើការវិភាគយុទ្ធសាស្ត្រទូលំទូលាយ និងកំណត់តម្រូវការក្នុងការដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ដោយបញ្ជ្រាបគោលការណ៍នានានៃការអភិវឌ្ឍដោយចីរភាពទៅក្នុងក្របខណ្ឌគោលនយោបាយជាតិ ពង្រឹងអភិបាលកិច្ចការគ្រប់គ្រងធនធានព្រៃឈើ និងការលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងការចូលរួមរបស់ភាគីពាក់ព័ន្ធ។ លើសពីនេះទៀត យុទ្ធសាស្ត្ររេដបូកជាតិ ក៏រួមបញ្ចូលផងដែរនូវគោលដៅ ក្នុងការបង្កើត និងពង្រឹងក្របខណ្ឌរចនាសម្ព័ន្ធ ដើម្បីគ្រប់គ្រងការអនុវត្តរេដបូក។

### ៥.១ វិសាលភាព និងកម្រិតអនុវត្តន៍

វិសាលភាពដំបូងនៃយុទ្ធសាស្ត្ររេដបូកជាតិ នឹងផ្តោតលើការដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ (វាស់វែងតាមរយៈការផ្លាស់ប្តូរការប្រើប្រាស់ដី និងការបម្លែងដីព្រៃឈើ) ហើយទន្ទឹមនឹងនេះ កសាងសមត្ថភាពជាបណ្តើរៗដើម្បីដោះស្រាយបុព្វហេតុនៃការរេចរិលព្រៃឈើ។ កម្ពុជានឹងឈានទៅប្រតិបត្តិពេញលេញកម្រិតជាតិ ក្នុងការអនុវត្តយន្តការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផល ដែលស្ថិតនៅក្រោមអនុសញ្ញា UNFCCC នឹងពិចារណាលើការអនុវត្តសកម្មភាពរេដបូកនានានៅថ្នាក់ក្រោមជាតិ និងពិចារណាលើប្រភពធនធានហិរញ្ញប្បទានដែលផ្អែកលើយន្តការទីផ្សារ។

### ៥.២ ចំណុចខាស់ខែង និងលទ្ធផល

រយៈពេលសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ (ឆ្នាំ២០១៧-២០២៥) ត្រូវបានបែងចែកជាពីរដំណាក់។ នៅដំណាក់កាលទីមួយ ពីឆ្នាំ២០១៧ដល់ឆ្នាំ២០២០ ជាដំណាក់កាលអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ដែលនៅក្នុងដំណាក់កាលនេះ នឹងរួមបញ្ចូលទាំងការរៀបចំរចនាសម្ព័ន្ធ ការរៀបចំផែនការសកម្មភាព ការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិង

វាយតម្លៃ និងការកៀគរហិរញ្ញប្បទានជាមុន សម្រាប់វិនិយោគលើការអនុវត្តសកម្មភាព ដែលមិនផ្អែកលើលទ្ធផល។ ចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥ នឹងចាប់ផ្តើមប្រតិបត្តិយន្តការទូទាត់ដោយផ្អែកលើលទ្ធផល ដោយផ្ទៀងផ្ទាត់និងចំណុចវាស់វែងដែលបានកំណត់ស្តីពីការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅត្រឹមឆ្នាំ២០២៥។

## ៥.៣ គោលការណ៍ណែនាំ

- ការរួមចំណែករបស់កម្ពុជានៅក្នុងការសម្រេចបានសមិទ្ធផលនៃគោលបំណងនានា ដូចមានចែងនៅក្នុងមាត្រា២ និងការប្តេជ្ញានានា ដូចមានចែងក្នុងមាត្រា៤ វាក្យខណ្ឌ៣ នៃអនុសញ្ញា UNFCCC
- ផ្អែកលើយន្តការសម្របសម្រួលដែលមានស្រាប់ រាជរដ្ឋាភិបាលកម្ពុជាគាំទ្រដល់ការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនានារបស់ជាតិ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព
- ជម្រុញការចូលរួមរបស់វិស័យពាក់ព័ន្ធ និងការសម្របសម្រួល ការអនុវត្តគោលនយោបាយ និងវិធានការរេដបូក (PAMs) ដើម្បីធានាថាបុព្វហេតុដោយផ្ទាល់ និងប្រយោលនៃការបាត់បង់ និងការរេចរិលព្រៃឈើត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធិភាព
- ស្វែងរកហិរញ្ញប្បទានដែលអាចព្យាករណ៍បាន ឲ្យបានគ្រប់គ្រាន់សម្រាប់គាំទ្រការអនុវត្ត និងពង្រីកយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដែលមានស្រាប់
- ធានាថាអ្នកពាក់ព័ន្ធទាំងអស់បានចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងក្រុមជនងាយរងគ្រោះដូចជា សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងក្រុមស្ត្រីផងដែរ
- កសាងសមត្ថភាពនៅក្នុងស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ
- មានសង្គតិភាពជាមួយដំណើរការនៃការចរចាជាអន្តរជាតិ នៅក្រោមអនុសញ្ញា UNFCCC និងវិធីសាស្ត្រនានាដែលបានបង្កើតឡើងដោយក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)។

## ៥.៤ ការវិភាគយុទ្ធសាស្ត្រ

### ៥ ៤.១.ការបន្សុីជាមួយគោលបំណង និងអាទិភាពដទៃទៀតនៃការអភិវឌ្ឍជាតិ

ផែនទីបង្ហាញផ្លូវសម្រាប់ការត្រៀមអនុវត្តរេដបូក និងសមិទ្ធផលបានពីសកម្មភាពនានា ដែលបានធ្វើឡើងនៅក្នុងពេលអនុវត្តផែនទីបង្ហាញផ្លូវ គឺជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ ផែនទីបង្ហាញផ្លូវនេះ គឺជាលទ្ធផលនៃការពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយអ្នកពាក់ព័ន្ធជាច្រើនផ្សេងៗគ្នា តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។ លើសពីនេះ យុទ្ធសាស្ត្ររេដបូកជាតិ មានទំនាក់ទំនង ដ៏ជិតស្និទនឹងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីជាតិសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថាន ដែលមានក្នុងពេលបច្ចុប្បន្ន និងរួមចំណែកទៅក្នុងយុទ្ធសាស្ត្រ និងកម្មវិធីព្រៃឈើជាតិ។

យុទ្ធសាស្ត្ររេដបូកជាតិ ត្រូវបានប្រមើលឃើញថា នឹងជួយគាំទ្រ និងបំពេញបន្ថែមចំពោះការអនុវត្តផែនការអភិវឌ្ឍ ដ៏ធំទូលាយ ហើយមិនបង្កើតឲ្យមានផែនការ និងរចនាសម្ព័ន្ធស្របគ្នា ឬប្រជែងគ្នាសម្រាប់ការគ្រប់គ្រងព្រៃឈើនៅកម្ពុជាឡើយ។ ពិសេសជាងនេះទៀត ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវបានពិចារណាដោយហ្មត់ចត់នូវគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីជាតិនានា ដូចជា៖

- ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ (សេចក្តីព្រាងកំពុងស្ថិតក្នុងការរៀបចំ មានសេចក្តីដកស្រង់ខ្លះៗ)

- ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣
- ក្របខណ្ឌយុទ្ធសាស្ត្រ និងគោលនយោបាយបញ្ច្រាបយេនឌ័រលើវិស័យកសិកម្ម
- យុទ្ធសាស្ត្រចតុកោណ ជំហានទី៣ ឆ្នាំ២០១៣-២០១៨
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) ឆ្នាំ២០១៤-២០១៨
- សូចនាករតាមដានត្រួតពិនិត្យរួមគ្នា ឆ្នាំ២០១៤-២០១៨
- ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០១៨
- ផែនការយុទ្ធសាស្ត្រនារីរតនៈ ឆ្នាំ២០១៤-២០១៨
- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតងឆ្នាំ២០១៣-២០៣០
- របាយការណ៍ជាតិលើកដំបូង និងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ ។

### ៥ ៤.២.ទិដ្ឋភាពរួមនៃការគ្រប់គ្រងដីព្រៃ

ព្រៃបម្រុងទុកអចិន្ត្រៃយ៍ស្ថិតក្រោមដែនសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល) ទទួលខុសត្រូវលើការងារគ្រប់គ្រងព្រៃឈើ ព្រៃលិចទឹកនិងព្រៃកោងកាង ហើយក្រសួងបរិស្ថាន (អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន) ទទួលខុសត្រូវការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយរួមទាំងតំបន់ស្នូលនៃបឋមនីយជីវមណ្ឌលបឹងទន្លេសាប។ ព្រៃឈើមានមុខងារសំខាន់ ក្នុងការបង្កើតមុខរបរចិញ្ចឹមជីវិតនៅតាមជនបទ ដោយបានផ្តល់អេកូឡូស៊ីដ៏មានតម្លៃ និងធនធានសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍប្រទេស។

ដោយគិតជាមធ្យម ធនធានព្រៃឈើបានផ្តល់ប្រភពថាមពលសម្រាប់ប្រើប្រាស់ក្នុងគ្រួសារប្រមាណពី ១០% ទៅ ២០% ប៉ុន្តែគម្របព្រៃឈើប្រទេសកម្ពុជា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗកន្លងមកនេះ។ នៅចន្លោះឆ្នាំ១៩៦៤ ដល់ឆ្នាំ២០១៤ កម្ពុជាបានបាត់បង់គម្របព្រៃឈើនៅទូទាំងប្រទេសប្រមាណមួយភាគប្រាំ ដែលជាលទ្ធផលនៃការវិវត្តតួនាទីរបស់ព្រៃឈើ នៅក្នុងអាទិភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការវាយតម្លៃគម្របព្រៃឈើ ដោយរាប់បញ្ចូលផ្ទៃដីចំការកៅស៊ូ និងដូងប្រេងជាតំបន់ព្រៃឈើផងដែរ។ តាមប្រវត្តិនៃការវាយតម្លៃគម្របព្រៃឈើ នៅឆ្នាំ១៩៦៥ ផ្ទៃដីគម្របព្រៃឈើ មានអត្រាស្មើនឹង ៧៣,០៤% ធៀបនិងផ្ទៃប្រទេស និងជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៤ ឃើញថាអត្រានេះបានធ្លាក់ចុះមកនៅត្រឹម ៤៩,៤៨%។ លទ្ធផលមានបង្ហាញជូនក្នុងរូបភាពក្រាហ្វិចដូចខាងក្រោម៖

DRAFT




រូបភាពទី២៖ ក្រាហ្វិកបម្រែបម្រួលគម្របព្រៃឈើជាតិ ពីឆ្នាំ១៩៦៥ ដល់ ឆ្នាំ២០១៤

សម្រាប់គោលបំណងនៃការអនុវត្តកម្មវិធីរេដបូក ការវាយតម្លៃគម្របព្រៃឈើ សម្រាប់រៀបចំកម្រិតយោងព្រៃឈើជាតិ មិនរាប់បញ្ចូលផ្ទៃដីចំការកៅស៊ូ និងដូងប្រេង ជាផ្ទៃដីគម្របព្រៃឡើយ។ ដោយសម្រេចជ្រើសយកពេលវេលា ៨ឆ្នាំចុងក្រោយ គិតពីឆ្នាំ២០០៦សម្រាប់កសាងកម្រិតយោងព្រៃឈើជាតិ លទ្ធផលបង្ហាញថាធនធានព្រៃឈើនៅមានអត្រាស្មើនឹង ៥៩,៦៤% ហើយបានថយចុះមកត្រឹមអត្រា ៥៧,៥៥% នៅឆ្នាំ២០១០ និងបន្តធ្លាក់ចុះខ្លាំងនៅឆ្នាំ២០១៤ ដោយផ្ទៃដីគម្របព្រៃនៅសល់ត្រឹមចំនួន ៤៦,៩០% ប៉ុណ្ណោះ។ បើប្រៀបធៀបការបាត់បង់ធនធានគម្របព្រៃឈើក្នុងចន្លោះពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ អត្រានៃការបាត់បង់ព្រៃឈើមានការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងរយៈពេល៤ឆ្នាំចុងក្រោយ ដោយមានអត្រាថយចុះជាមធ្យមប្រចាំឆ្នាំស្មើនឹង ២,៦៦% ដែលមានចំនួនប្រមាណច្រើនជាង៥ដង ធៀបនឹងអត្រាផ្ទៃដីព្រៃឈើបានបាត់បង់នៅចន្លោះឆ្នាំ២០០៦ ដល់២០១០កន្លងមក ដែលមានអត្រាជាមធ្យមថយចុះប្រចាំឆ្នាំត្រឹមតែ០,៥% ប៉ុណ្ណោះ។ លទ្ធផលនេះចាត់ទុកជាប្រវត្តិសាស្ត្រដំបូងរបស់ប្រទេសកម្ពុជា ដែលអត្រាធនធានគម្របព្រៃឈើបានថយចុះយ៉ាងគំហុក ដោយបច្ចុប្បន្នទំហំផ្ទៃដីគម្របព្រៃឈើសរុបទូទាំងប្រទេសកម្ពុជា នៅសល់តិចជាង ១០លានហិកតា ដោយសារការអភិវឌ្ឍដំណាំកសិកម្ម និងតម្រូវការដីធ្លីរបស់ប្រជាពលរដ្ឋ ដែលមានកំណើនខ្ពស់។




រូបភាពទី៣៖ អត្រាថយចុះធនធានគម្របព្រៃឈើកម្ពុជា ចាប់ពីឆ្នាំ១៩៦៥-២០១៤ (សម្រាប់អនុវត្តកម្មវិធីរេដបូក)

## ៥ ៤.៣.មូលហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើនៅកម្ពុជា

ការបាត់បង់ និងការរេចរិលព្រៃឈើ មានបុព្វហេតុជាច្រើន ដូច្នេះគោលនយោបាយ និងវិធានការរេដបូកនានា ដើម្បីដោះស្រាយបុព្វហេតុទាំងនេះត្រូវមានលក្ខណៈប្លែកៗគ្នា អាស្រ័យទៅតាមកាលៈទេសៈ សមត្ថភាព និងលទ្ធភាពរបស់ជាតិ។

ការបាត់បង់ព្រៃឈើនៅកម្ពុជា ភាគច្រើនកើតឡើងនៅតំបន់ភ្នំ និងនៅតាមជួរភ្នំដែលមានព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។ ការប្រែប្រួលទាំងព្រៃស្រោង និងព្រៃល្បោះនៅតាមតំបន់ទំនាប ក៏ត្រូវបានកត់ត្រាផងដែរនៅក្នុងតំបន់វាលរាប។ លើសពីនេះ តំបន់ដែលមានការប្រែប្រួលព្រៃឈើខ្លាំងបំផុត ច្រើនស្ថិតនៅតំបន់ជាប់ព្រំដែនជាមួយប្រទេសឡាវ វៀតណាម និងថៃ។

ក្នុងឆ្នាំ២០១៤ ផ្ទៃដីសរុបដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឲ្យសម្រាប់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មមានចំនួនសរុបប្រមាណ ១,៧៥ លានហិកតា ក្នុងនោះផ្ទៃដីប្រមាណ ១,៣ លានហិកតា (ទិន្នន័យគិតត្រឹមឆ្នាំ២០១៤) ត្រូវបានផ្តល់ស្ថិតក្រោមការគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលើផ្ទៃដីទំហំប្រមាណ ៤៥ សែនហិកតា បានផ្តល់ក្រោមការគ្រប់គ្រងដោយក្រសួងបរិស្ថាន (អនុក្រឹត្យរាជរដ្ឋាភិបាលលេខ ៦៩ អ.ន.ក្រ.ប.ក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦)។ ថែមពីនេះ មានផ្ទៃដីមួយចំនួនទៀត ត្រូវបានផ្តល់សម្បទាន ដើម្បីសិក្សាស្រាវជ្រាវធនធានរ៉ែ ធនធានប្រេង និងឧស្ម័នធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះ ពីឆ្នាំ២០០៩-២០១៣ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយផ្តល់ដីសម្បទានសង្គមកិច្ចសម្រាប់កំណើនប្រជាពលរដ្ឋបច្ចុប្បន្ននិងពេលខាងមុខ ជនក្រីក្រខ្វះដីពិតប្រាកដ និងសម្រាប់បង្កើតជាភូមិអភិវឌ្ឍន៍ថ្មីៗ មានទំហំផ្ទៃដីប្រមាណ ១,២៥ សែនហិកតា (ឯកសារជំនួយស្មារតីរបស់រដ្ឋបាលព្រៃឈើរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ។ ក្រៅពីនេះ នៅក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាល បានសម្រេចអនុវត្តបទបញ្ជា ០០១ ប.ប ធ្វើអនុបយោគកាត់ផ្ទៃដីព្រៃរបស់រដ្ឋ ដើម្បីផ្តល់ប្លង់កម្មសិទ្ធជូនប្រជាជនលើទំហំផ្ទៃដីសរុប ១,២ លានហិកតា (សេចក្តីជូនដំណោងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦)។ ដោយឡែកនៅមានការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗទៀតក៏មានឥទ្ធិពលអវិជ្ជមានដល់ការបាត់បង់ព្រៃឈើដែរ ដូចជា ការកសាងប្រព័ន្ធផ្លូវថ្នល់កាត់តំបន់ព្រៃឈើ សាលារៀន និងមណ្ឌលសុខភាព។

ជាទូទៅ ការបាត់បង់ និងការរេចរិលព្រៃឈើ បានកើតឡើងដោយសារដំណើរការដ៏សាំញ៉ាំដែលរួមមាន៖

- លទ្ធភាពចូលទៅកាន់តំបន់ព្រៃឈើឆ្ងាយដាច់ស្រយាលមានភាពងាយស្រួល និងអសន្តិសុខសង្គម បានបង្កឲ្យមានសកម្មភាពកាប់ឈើជាលក្ខណៈពាណិជ្ជកម្មកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ (ដែលក្រោយមកត្រូវបានបញ្ឈប់នៅពេលដែលរាជរដ្ឋាភិបាលបានប្រកាសផ្អាកការកាប់ឈើនៅក្នុងឆ្នាំ២០០២) និងពេលថ្មីៗនេះដោយសារគម្រោងសាងសង់ផ្លូវថ្នល់ ទំនប់វារីអគ្គិសនី និងរ៉ែ
- ភាពមិនច្បាស់លាស់នៃសិទ្ធិប្រើប្រាស់ដីធ្លី និងការកើនឡើងតម្លៃដី ក៏ជាការលើកទឹកចិត្តឲ្យមានការទន្ទ្រានចាប់យកដីព្រៃ ដោយគ្រាន់តែផ្អែកលើសិទ្ធិក្នុងការតាំងទីលំនៅប៉ុណ្ណោះ ទោះបីជាល្មើសនឹងច្បាប់ភូមិបាល ឆ្នាំ២០០១ ក៏ដោយ
- សមត្ថភាព និងលទ្ធភាពរបស់សមត្ថកិច្ចនៅមានកម្រិត ដូច្នេះការគ្រប់គ្រងព្រៃឈើមិនបានគ្រប់គ្រាន់ ជាពិសេសព្រៃឈើដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ នៅតំបន់ឆ្ងាយដាច់ស្រយាល (នៅក្រោមច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ភូមិបាល)
- គោលនយោបាយ និងវិធានការនានាបានគាំទ្រដល់ការពង្រីកដីកសិកម្ម និងសកម្មភាពអភិវឌ្ឍន៍ទ្រង់ទ្រាយធំកើនឡើងយ៉ាងឆាប់រហ័ស បាននាំឲ្យមានការពង្រីកឆ្ការរានដីព្រៃឈើយ៉ាងធំទូលាយនៅតំបន់មួយចំនួនដែលបានប្រកាសជាតំបន់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច (ELCs និង SLCs)
- កំណើនសេចក្តីត្រូវការវត្ថុធាតុដើមនៅថ្នាក់តំបន់ និងពិភពលោក ដូចជាឈើ កៅស៊ូ និងស្ករស
- ការកើនឡើងចំនួនប្រជាជន និងតម្រូវការដីកសិកម្ម

– ភាពក្រីក្រនៅតាមជនបទ។

បុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ក៏កើតចេញពីប្រភពខាងក្រៅវិស័យព្រៃឈើផងដែរ ហើយបុព្វហេតុទាំងនេះមិនងាយនឹងបែងចែកឲ្យដាច់ស្រឡះពីគ្នា រវាងបុព្វហេតុនៃការបាត់បង់ព្រៃឈើពីប្រភពខាងក្រៅ និងប្រភពខាងក្នុងវិស័យព្រៃឈើឡើយ។ បុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ពីប្រភពខាងក្រៅវិស័យព្រៃឈើមានដូចជា តម្រូវការប្រើប្រាស់ដីព្រៃឈើពីវិស័យផ្សេងៗ កំណើនប្រជាពលរដ្ឋ កំណើនទីផ្សារឈើទាំងក្នុង និងក្រៅប្រទេស។ល។

## ៥ ៤.៤.បុព្វហេតុសំខាន់ៗដែលត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិ

ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិឲ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ មានទំនាក់ទំនងដ៏សំខាន់ទៅនឹងការរៀបចំ និងការអនុវត្តឲ្យបានពេញលេញនូវទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ដោយជម្រុញឲ្យមានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការបង្កើនសន្និធិកាបូនព្រៃឈើ និងការអភិរក្សព្រៃឈើ ។

ដូចបានបង្ហាញនៅផ្នែកខាងដើម បុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ មានប្រភពមកពីខាងក្រៅ និងប្រភពមកពីខាងក្នុងវិស័យព្រៃឈើ ដូច្នេះយុទ្ធសាស្ត្ររេដបូកជាតិ នឹងមិនអាចសម្រេចបានឡើយ ក្នុងករណីយុទ្ធសាស្ត្រនេះព្យាយាមដោះស្រាយគ្រប់បុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ។ ដូច្នេះ ដើម្បីកំណត់ និងចាត់អាទិភាពបុព្វហេតុនៃការបាត់បង់ព្រៃឈើ ដែលចាំបាច់ត្រូវដោះស្រាយតាមរយៈការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ សកម្មភាពសំខាន់មួយចំនួននឹងត្រូវបានអនុវត្តដូចខាងក្រោម៖

សកម្មភាពទីមួយគឺ ការពិនិត្យលើឯកសារដែលបានសិក្សាកន្លងមកអំពីបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ជាពិសេស ការពិនិត្យឯកសារដែលបានប្រើប្រាស់ ដើម្បីរៀបចំគោលនយោបាយជាតិនាពេលបច្ចុប្បន្នដូចជា៖ កម្មវិធីព្រៃឈើជាតិ (NFP) ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ (NPASMP) និងក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល (SPFF)។ សកម្មភាពទីពីរ គឺការពិគ្រោះយោបល់ជាមួយអ្នកជំនាញបច្ចេកទេសពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល អំពីលទ្ធភាពដែលពាក់ព័ន្ធនឹងសង្គម នយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យា ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើដែលបានរកឃើញ និងលទ្ធភាពនៃការតាមដានត្រួតពិនិត្យលទ្ធផលតាមរយៈប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ។ លទ្ធផល ទាំងអស់នេះត្រូវដាក់ពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលដឹកនាំសម្របសម្រួលការអនុវត្តកម្មវិធីរេដបូកជាតិ។ នៅទីបញ្ចប់ កិច្ចប្រជុំពិគ្រោះយោបល់ ត្រូវបានធ្វើឡើងជាមួយសមាជិកក្រុមការងាររេដបូកជាតិ ក្រុមបច្ចេកទេសរេដបូក ក្រុមពិគ្រោះយោបល់រេដបូក ក្រុមយេនឌ័ររេដបូក និងមន្ត្រីជំនាញពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

តាមរយៈដំណើរការពិគ្រោះយោបល់ បុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ដែលយុទ្ធសាស្ត្ររេដបូកជាតិនឹងត្រូវដោះស្រាយនៅក្នុងរយៈពេលបួនឆ្នាំខាងមុខ (ឆ្នាំ២០១៧-២០២០) ត្រូវបានកំណត់ចាត់អទិភាពដូចមានបង្ហាញក្នុងតារាងទី១។ សេចក្តីសម្រេចដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ ក៏បានពិចារណាផងដែរអំពី ១)លទ្ធភាពដែលអាចដោះស្រាយបាននូវបុព្វហេតុនៃការបាត់បង់ព្រៃឈើទាំងនោះ ២)សក្តានុពលក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ៣)សមត្ថភាពបច្ចេកទេសក្នុងការតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់លទ្ធផល ដែលយុទ្ធសាស្ត្របានជ្រើសយកបុព្វហេតុនៃការបាត់បង់ព្រៃឈើទាំងនេះមកដោះស្រាយ និង៤)មានសក្តានុពលទាក់ទាញការចូលរួមពីសហគមន៍មូលដ្ឋាន ជាពិសេសជនជាតិដើមភាគតិច និងស្ត្រី។ នៅពេលដែលទិន្នន័យ និងវិធីសាស្ត្រនៃប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ មានភាពប្រសើរឡើង គោលនយោបាយ និងវិធានការរេដបូក សម្រាប់ដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើដទៃទៀត នឹងត្រូវ

បានដាក់បញ្ចូលបន្ថែម។ ជាការចាំបាច់ គោលនយោបាយ និងវិធានការរេដបូក ដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ គឺជាអាទិភាពដែលត្រូវអនុវត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ នឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមដានលើប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ តាមរយៈយន្តការទទួលយោបល់ឆ្លើយតបនៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក។ លើសពីនេះទៀត វិធីសាស្ត្រ និងសកម្មភាពនៅតាមទីវាលជាក់ស្តែង ត្រូវរៀបចំកែលម្អ និងបង្កើតថ្មីជាបន្តបន្ទាប់បន្ថែមទៀតតាមការចាំបាច់និងតាមបទពិសោធន៍ទទួលបានពីការអនុវត្ត ដែលជាលទ្ធផលសម្រេចបានពីការអនុវត្តតាមអភិក្រមជាជំហាន ឬវិធីសាស្ត្រជាជំហាន (stepwise approach) គឺការតាមដានត្រួតពិនិត្យ ការទទួលយោបល់ឆ្លើយតប ការរៀនសូត្រ និងការកែលម្អយុទ្ធសាស្ត្ររេដបូកជាតិ។

**តារាងទី១៖ បុព្វហេតុនៃការបាត់បង់ព្រៃឈើដែលនឹងត្រូវដោះស្រាយពីឆ្នាំ២០១៧-២០២០**

| ប្រភេទ | បុព្វហេតុនៃការបាត់បង់ព្រៃឈើ ដែលត្រូវដោះស្រាយពីឆ្នាំ២០១៧-២០២០ |
|---|---|
| បុព្វហេតុផ្ទាល់ | ១.ការបម្លែងដីព្រៃឈើ<br>– ការអភិវឌ្ឍកសិកម្មនិងកសិ-ឧស្សាហកម្ម (ដូចជា សម្បទានដីសេដ្ឋកិច្ច)<br>– ការតាំងទីលំនៅ និងដីកសិកម្ម (ដូចជា សម្បទានដីសង្គមកិច្ច គោលនយោបាយចាស់សកម្មភាពថ្មី)<br>– ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ(ដូចជា ការសាងសង់ផ្លូវថ្នល់ ទំនប់វារីអគ្គិសនី)<br>– ការធ្វើអាជីវកម្មរ៉ែ ដោយមិនអនុវត្តន៍តាមបទដ្ឋានបច្ចេកទេស<br>២. ការទន្ទ្រានយកដីព្រៃឈើ<br>– ការទន្ទ្រានកាន់កាប់ដីព្រៃឈើ យកធ្វើកម្មសិទ្ធិ និងជួញដូរ<br>៣. ការរេចរិលព្រៃឈើ<br>– ការកាប់ឈើខុសច្បាប់<br>– ការប្រមូលផល និងអនុផលព្រៃឈើមិនមាននិរន្តភាព |
| បុព្វហេតុប្រយោល | – អភិបាលកិច្ចក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីនៅមានកម្រិត<br>– កង្វះការសម្របសម្រួលរវាងអន្តរក្រសួងលើការរៀបចំផែនការប្រើប្រាស់ដី<br>– ភាពក្រីក្រនៅជនបទ ដោយសារខ្វះជម្រើសមុខរបរសម្រាប់ជីវភាពរស់នៅ<br>– ការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធនៅមានកម្រិត<br>– កង្វះធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់រយៈពេលវែង ដើម្បីគាំទ្រដល់វិស័យព្រៃឈើ<br>– ពុំមានទិន្នន័យគ្រប់គ្រាន់ សម្រាប់បង្កើតវិធានការទប់ស្កាត់ឧក្រិដ្ឋកម្ម ព្រៃឈើឲ្យមានប្រសិទ្ធភាព |

DRAFT

## ៥ ៤.៥.សក្តានុពលនៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងសហប្រយោជន៍នៅក្នុងប្រទេសកម្ពុជា

ទោះបីជាមានអត្រានៃការបាត់បង់ព្រៃឈើមួយចំនួនក៏ដោយ ក៏ប្រទេសកម្ពុជា មានសក្តានុពលខ្ពស់ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងការរេចរិលព្រៃឈើ និងការបង្កើនសន្និធិកាបូនព្រៃឈើ។ ការប៉ាន់ប្រមាណដោយផ្អែកលើផែនទីគម្របព្រៃឈើឆ្នាំ២០១៤ បានបង្ហាញថា មានសន្និធិកាបូនឌីអុកស៊ីតប្រមាណជា ២,៤១ ជីហ្គាតោន ត្រូវបានរក្សាទុកនៅក្នុងព្រៃរបស់ប្រទេសកម្ពុជា ដែលបរិមាណនេះបានធ្លាក់ចុះបើធៀបនឹងសន្និធិកាបូនឌីអុកស៊ីតនៅឆ្នាំ២០០៦ ដែលមានរហូតដល់ ២,៩៧ ជីហ្គាតោន ដោយយោងតាមទិន្នន័យគម្របព្រៃឈើ ក្នុងឯកសារកម្រិតយោងព្រៃឈើជាតិ។

តំបន់ធំបំផុតប្រកបដោយដង់ស៊ីតេកាបូនខ្ពស់ ត្រូវបានរកឃើញនៅក្នុងព្រៃស្រោង ជួរភ្នំក្រវាញនៅភាគនិរតីប្រទេស។ កម្រិតដង់ស៊ីតេកាបូនខ្ពស់ ត្រូវបានកំណត់ថា ជាតំបន់ដែលមានសន្និធិកាបូនប្រមាណ ២០% ធៀបនឹងសន្និធិកាបូនសរុប គ្របដណ្តប់លើផ្ទៃដីប្រមាណ ១២% ធៀបនិងនៃផ្ទៃដីប្រទេស។ ដោយឡែក តំបន់ដង់ស៊ីតេកាបូនខ្ពស់កម្ពុជា មានសន្និធិកាបូនប្រមាណ ៤០% ធៀបនឹងសន្និធិកាបូនទូទាំងប្រទេសកម្ពុជា និងគ្របដណ្តប់លើផ្ទៃដីតិចជាង ២៣% ធៀបនិងផ្ទៃដីប្រទេស។ ការប៉ាន់ប្រមាណបរិមាណកាបូនស្តុកទុកនៅក្នុងប្រព័ន្ធអេកូឡូស៊ីព្រៃឈើប្រទេសកម្ពុជាបានបង្ហាញថា សន្និធិកាបូនព្រៃឈើនៅក្នុងតំបន់សម្បទានព្រៃឈើ ព្រៃផ្តល់ផល និងព្រៃអចិន្ត្រៃយ៍មាន៣០% សន្និធិកាបូននៅក្នុងតំបន់ការពារមាន២៦% សន្និធិកាបូននៅក្នុងតំបន់ដីព្រៃដែលបានបន្លែងជាដីសម្បទានសេដ្ឋកិច្ច ដែលគ្រប់គ្រងដោយក្រុមហ៊ុនសម្បទានមាន១២% និងសន្និធិកាបូននៅក្នុងតំបន់ព្រៃផ្សេងៗ និងតំបន់ដទៃទៀតដូចជា ព្រៃឈើឯកជន ឬ ចំការដែលការទទួលខុសត្រូវគ្រប់គ្រងមិនទាន់ច្បាស់មាន១៩% ។

ការបាត់បង់ និងការរេចរិលព្រៃឈើរួមចំណែកប្រហែល១៧% នៃការបំភាយឧស្ម័នផ្ទះកញ្ចក់ជាសកល។ ការបាត់បង់គម្របព្រៃឈើនៅក្នុងប្រទេសកម្ពុជា ជាប់ទាក់ទងសំខាន់ នឹងការផ្លាស់ប្តូរការប្រើប្រាស់ដី ដែលនេះគឺជាបុព្វហេតុដែលធ្វើឲ្យប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ព្រៃឈើមានមុខងារជាអាងស្តុកឧស្ម័នផ្ទះកញ្ចក់ដ៏សំខាន់បំផុតតែមួយគត់នៅកម្ពុជា។ បើយោងតាមទិន្នន័យសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់របស់ក្រសួងបរិស្ថាន បង្ហាញថា នៅឆ្នាំ២០០០ ប្រទេសកម្ពុជាបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចំនួន ៤៧.០០០ ជីហ្គាតោន ហើយនៅឆ្នាំដដែលនេះ គម្របព្រៃឈើកម្ពុជា បានស្រូបយកឧស្ម័នផ្ទះកញ្ចក់ដែលបានបញ្ចេញទៅបរិយាកាសជាងពាក់កណ្តាល គឺមានចំនួន ២៤.៥០០ ជីហ្គាតោន។ ការបាត់បង់ និងការរេចរិលគម្របព្រៃឈើ មានន័យថាសក្តានុពលនៃការស្រូបយកឧស្ម័នផ្ទះកញ្ចក់មានការថយចុះ។

ការព្យាករណ៍វិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជាបង្ហាញថា ព្រៃឈើនឹងរងផលប៉ះពាល់ ដោយការផ្លាស់ប្តូរសីតុណ្ហភាព របបទឹកភ្លៀង និងការផ្លាស់ប្តូររដូវកាល។ របាយការណ៍ជាតិលើកទីពីរឆ្នាំ២០១៦ ដែលក្រសួងបរិស្ថានបានដាក់ជូនអនុសញ្ញា UNFCCC បានបង្ហាញថា ព្រៃឈើដែលស្ថិតក្នុងស្ថានភាពស្ងួតហែងយូរ អាចកាត់បន្ថយផលិតភាពព្រៃឈើ ជីវចម្រុះ និងមានហានិភ័យភ្លើងឆេះព្រៃកើនឡើង។ ប្រសិនបើព្រៃឈើត្រូវបានកាប់ឆ្ការ ហានិភ័យដែលកើតមានឡើង គឺនៅតំបន់នោះត្រូវការរយៈពេលដ៏យូរដើម្បីឲ្យព្រៃឈើអាចមានលទ្ធភាពដុះឡើងវិញ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុអាចមានផលវិបាកជាច្រើនទៀត។ ព្រៃឈើផ្តល់សារៈសំខាន់សម្រាប់ការចិញ្ចឹមជីវិតនៅតាមជនបទ ការបាត់បង់ផលិតភាពព្រៃឈើ ក៏ដូចជាជីវចម្រុះ នឹងនាំឱ្យមានការខាតបង់ប្រាក់ចំណូល និងជម្រើសនានាសម្រាប់ការចិញ្ចឹមជីវិតរបស់សហគមន៍ដែលអាស្រ័យផលលើព្រៃឈើ និងសហគមន៍ដែលរស់នៅជិតតំបន់ព្រៃ។ កត្តានេះអាចបង្កអោយវដ្តនៃការលូតលាស់របស់សត្វល្អិតមួយចំនួនមានការផ្លាស់ប្តូរ ដែលអាចមានផលប៉ះពាល់ដល់កសិកម្ម និងព្រៃឈើ។ ផ្ទុយទៅវិញ ការរក្សាគម្របព្រៃឈើបានល្អ មានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងការថែរក្សាប្រភពផ្គត់ផ្គង់ទឹកស្អាត គុណភាពដី និងគម្របដី

DRAFT

ហើយទំនាក់ទំនងនេះអាចទទួលរងផលអវិជ្ជមានផងដែរ។ ការបាត់បង់ព្រៃឈើអាចនាំឲ្យមានផលវិបាកផ្សេងៗដូចជា ខ្យល់ព្យុះ ការហូរច្រោះដី និងការបាក់ដី។

សន្និធិកាបូនដែលមាននៅលើដីនៃប្រទេសកម្ពុជា ភាគច្រើនមាននៅក្នុងតំបន់ដែលមានសក្តានុពលក្នុងការផ្តល់ប្រយោជន៍បានច្រើនយ៉ាង និងមានសារៈសំខាន់សម្រាប់អភិរក្សជីវចម្រុះ ហើយភាគច្រើននៃតំបន់ទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងការពារ។ ដូច្នេះ ការធ្វើសកម្មភាពដើម្បីការពារតំបន់ទាំងនេះ ដូចជាការពារសន្និធិកាបូន និងការកែលម្អការគ្រប់គ្រង គឺអាចឲ្យយើងសម្រេចបានការការពារជីវចម្រុះដែលមានទំនាក់ទំនងនិងសហប្រយោជន៍ជាច្រើនទៀត។

កម្ពុជាស្ថិតនៅក្នុងស្ថានភាពដែលអាចកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ តាមរយៈនៃការកាត់បន្ថយការបាត់បង់ព្រៃឈើ និងការពង្រីកតំបន់ដែលអាចស្រូបយកកាបូន។ ការការពារព្រៃឈើ តំបន់ទីជម្រាល និងដី នឹងអាចចូលរួមចំណែកដល់ការការពារប្រព័ន្ធអេកូឡូស៊ី ការគ្រប់គ្រងប្រភពទឹក ការប្រើប្រាស់ដី និងការធ្វើកសិកម្មប្រកបដោយនិរន្តភាព និងផ្តល់ប្រយោជន៍ដល់សុខមាលភាពមនុស្ស។ លើសពីនេះ ការអភិរក្សជីវចម្រុះអាចធ្វើឲ្យសេវាបរិស្ថានប្រសើរឡើង ព្រមទាំងផ្តល់សហប្រយោជន៍បន្ថែមទៀត។

ធនធានព្រៃឈើដ៏សំបូរបែបក្នុងប្រទេសកម្ពុជា មានមុខងារសំខាន់ទ្រទ្រង់ជីវភាពរស់នៅដល់ប្រជាពលរដ្ឋនៅជនបទ និងផ្តល់នូវធនធានសេដ្ឋកិច្ច និងប្រព័ន្ធអេកូឡូស៊ីដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍន៍ប្រទេសទាំងមូល។ ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព មានសារសំខាន់ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី តំបន់ផ្គត់ផ្គង់ទឹកស្អាត និងការពារជីវចម្រុះ។ កម្ពុជាទទួលស្គាល់ថាតាមរយៈនៃការគ្រប់គ្រងព្រៃឈើ កម្ពុជានឹងមានសក្តានុពលខ្ពស់ ក្នុងការស្រូបយកហិរញ្ញវត្ថុពីការប្រែប្រួលអាកាសធាតុដែលអាចផ្តល់ជាប្រយោជន៍ដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្ស។

មានប្រជាជនជិត៤លាននាក់ រស់នៅក្នុងចម្ងាយមិនលើស៥ គីឡូម៉ែត្រពីព្រៃឈើ។ ធនធានព្រៃឈើបានផ្គត់ផ្គង់បំពេញសេចក្តីត្រូវការប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាមធ្យមបានប្រមាណពី១០% ទៅ ២០%។ ភាគច្រើននៃប្រជាពលរដ្ឋនៅជនបទ (ប្រមាណ៨៤%) ពឹងផ្អែកលើថាមពលអុស និងធ្យូង។ ធនធានព្រៃឈើ ជាពិសេសអនុផលព្រៃឈើបានផ្តល់ការធានាសុវត្ថិភាពយ៉ាងសំខាន់ដល់ប្រជាពលរដ្ឋនៅជនបទក្នុងពេលមានគ្រោះអាសន្ន។ ការអភិវឌ្ឍន៍ធនធានមនុស្ស គឺជាកត្តាដ៏សំខាន់ទាក់ទងនឹងលទ្ធភាពក្នុងការប្រើប្រាស់ធនធានព្រៃឈើ និងដីព្រៃឈើដោយនិរន្តភាព។

## ៥.៥ ទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ

### ទិសដៅយុទ្ធសាស្ត្រទី១៖ កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យធនធានព្រៃឈើ និងការប្រើប្រាស់ដីព្រៃឈើ

<u>យុទ្ធសាស្ត្រ</u>

- លើកកម្ពស់សុវត្ថិភាពគ្រប់គ្រងដីព្រៃឈើតាមរយៈ ការចាត់ថ្នាក់ ការកំណត់តំបន់ និងការកំណត់ព្រំប្រទល់ព្រៃឈើ និងការចុះបញ្ជីកាដីព្រៃឈើ
- ពង្រឹងការអនុវត្តច្បាប់ក្នុងការទប់ស្កាត់ការបាត់បង់ និងការរេចរិលព្រៃឈើ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ
- តាមដានត្រួតពិនិត្យស្ថានភាពសម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ចដែលមានស្រាប់ ដើម្បីពិនិត្យអនុលោមភាព និងពង្រឹងសមត្ថភាពតាមដានត្រួតពិនិត្យការអនុវត្តឲ្យមានប្រសិទ្ធភាព
- ពង្រឹងការគ្រប់គ្រងតំបន់អភិរក្សព្រៃឈើ (តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សព្រៃលិចទឹក និងព្រៃកោងកាង)

- ពង្រឹងប្រព័ន្ធ និងសមត្ថភាពបច្ចេកទេសក្នុងការប្រមូល ការគ្រប់គ្រង ដំណើរការ ការបញ្ចូល ការធានាគុណភាព និងការតាមដានត្រួតពិនិត្យគុណភាពទិន្នន័យព្រៃឈើ និងការប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាព និងនិរន្តភាព
- រួមចំណែកក្នុងការធ្វើសនិទានកម្ម (ការធានាថាគ្មានភាពត្រួតគ្នានៃតួនាទី និងការទទួលខុសត្រូវ) នៃក្របខ័ណ្ឌច្បាប់សម្រាប់ការប្រើប្រាស់ដីធ្លី និងធនធានព្រៃឈើ
- កាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន ដែលនឹងកើតចេញពីការអនុវត្តសកម្មភាពក្នុងការទប់ស្កាត់ការបាត់បង់ និងការរេចរិលនៃព្រៃឈើ ទាំងក្នុង និងក្រៅវិស័យព្រៃឈើ ដូចជាការអភិវឌ្ឍរចនាសម្ព័ន្ធផ្លូវថ្នល់ជាដើម ។

## ទិសដៅយុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការអនុវត្តសកម្មភាពគ្រប់គ្រងព្រៃឈើដោយនិរន្តភាព

### យុទ្ធសាស្ត្រ

- ពង្រឹង និងពង្រីកវិសាលភាពតំបន់គ្រប់គ្រងធនធានព្រៃឈើដោយសហគមន៍មូលដ្ឋាន
- លើកទឹកចិត្តវិស័យឯកជនក្នុងការអនុវត្តសង្វាក់ផ្គត់ផ្គង់ដោយនិរន្តរភាពពីចំការឈើដាំ ដើម្បីជាជម្រើសជួយកាត់បន្ថយការបាត់បង់ និងការរេចរិលព្រៃឈើ
- បង្កើនការដាំព្រៃឈើ ការស្តារព្រៃឈើ និងការអនុវត្តរុក្ខវប្បកម្មនៅលើដីព្រៃរបស់រដ្ឋ
- លើកកម្ពស់ការផ្គត់ផ្គង់ឈើពីប្រភពចំការឈើដាំលើដីឯកជន តាមរយៈការបំលែងដីកសិកម្មរេចរិល ដើម្បីកាត់បន្ថយសំពាធលើព្រៃធម្មជាតិ
- លើកកម្ពស់ការផ្គត់ផ្គង់ឈើដែលមានប្រភពពីសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ ដើម្បីកាត់បន្ថយតម្រូវការឈើ និងការផ្គត់ផ្គង់ថាមពលដែលមានប្រភពពីឈើ
- លើកកម្ពស់ការគ្រប់គ្រងការប្រើប្រាស់ព្រៃឈើ ដីព្រៃឈើ និងអនុផលព្រៃឈើប្រកបដោយប្រសិទ្ធភាព សមភាព និងនិរន្តភាព
- បង្កើតជម្រើសមុខរបរចិញ្ចឹមជីវិតសមស្របដល់សហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកដល់ការកាត់បន្ថយការបាត់បង់ និងការរេចរិលព្រៃឈើ។

## ទិសដៅយុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធ ការបង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងដើម្បីអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

### យុទ្ធសាស្ត្រ

- បញ្ជ្រាបគោលនយោបាយ និងវិធានការរេដបូក ទៅក្នុងគោលនយោបាយជាតិ និងវិស័យពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ និងបង្កើនហិរញ្ញវត្ថុបន្ថែមសម្រាប់គាំទ្រដល់វិស័យព្រៃឈើ និងវិស័យពាក់ព័ន្ធ
- កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តការកាត់បន្ថយការបាត់បង់ និងការរេចរិលព្រៃឈើ

DRAFT

- ពង្រឹងរចនាសម្ព័ន្ធ និងក្របខណ្ឌសម្របសម្រួល ដើម្បីធានាឲ្យមានសង្គតិភាពគោលនយោបាយជាតិ ក្នុងការដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ នៅក្នុងគម្រោងអភិវឌ្ឍន៍ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ
- លើកទឹកចិត្តការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ នៅចំណុចចាប់ផ្តើមនៃការរៀបចំផែនការវិស័យព្រៃឈើ និងការប្រើប្រាស់ដី ព្រមទាំងលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ រួមទាំង អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន ក្រុមជនជាតិដើមភាគតិច យុវជន ស្ត្រី និងវិស័យឯកជន
- ពង្រឹងតួនាទីគ្រឹះស្ថានសិក្សា និងវិទ្យាស្ថានស្រាវជ្រាវ ក្នុងការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យាស្តីពីគោលនយោបាយព្រៃឈើ ការប្រើប្រាស់ដី និងរេដបូក
- កៀគរដៃគូអភិវឌ្ឍន៍ដើម្បីសហការបង្កើនធនធានមនុស្ស ចំណេះដឹងទាក់ទងវិស័យព្រៃឈើ ការប្រើប្រាស់ដី និងអភិបាលកិច្ចការប្រែប្រួលអាកាសធាតុ។

## ៦. តំណាក់កាល

យុទ្ធសាស្ត្ររេដបូកជាតិ ផ្តល់ក្របខណ្ឌធំទូលាយសម្រាប់ការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។ កម្ពុជាត្រូវរៀបចំផែនការសកម្មភាព និងក្របខណ្ឌអនុវត្តរេដបូកមួយ ដោយរួមបញ្ចូលទាំងក្របខណ្ឌអនុវត្ត យន្តការគ្រប់គ្រងហិរញ្ញប្បទានដោយនិរន្តភាព ក្របខណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងក្របខណ្ឌច្បាប់សម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ និងដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការកៀគរធនធានហិរញ្ញវត្ថុ។

### ៦.១ ដំណាក់កាលអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

<u>ដំណាក់កាលទី១ ពីឆ្នាំ២០១៧ ដល់២០២០ (តំណាក់កាលអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ)</u>

នៅក្នុងដំណាក់កាលនេះ ផែនការសកម្មភាពជាអាទិភាពពិស្តារមួយសម្រាប់ឆ្នាំ២០១៧-២០២០ នឹងត្រូវរៀបចំឡើងដោយរួមបញ្ចូលផែនការសកម្មភាពជាក់លាក់ សម្រាប់ការប្រមូលផ្តុំនិងចែករំលែកចំណេះដឹង និងការសម្របសម្រួល។ ផែនការយុទ្ធសាស្ត្រដំបូងត្រូវបានរួមបញ្ចូលនៅក្នុងឯកសារប្រវត្តិនៃផែនការយុទ្ធសាស្ត្ររេដបូកជាតិ។ ការគ្រប់គ្រងរចនាសម្ព័ន្ធ និងហិរញ្ញវត្ថុសម្រាប់សម្របសម្រួលការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ក៏នឹងត្រូវធ្វើឡើងផងដែរ ដោយរួមជាមួយនឹងការបង្កើតក្របខណ្ឌជាតិសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ សកម្មភាពដទៃទៀតដែលត្រូវធ្វើឲ្យបានសម្រេចរួមមាន៖

- ការសាកល្បងអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ សម្រាប់ប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់នៅថ្នាក់ជាតិ
- ការសាកល្បងអនុវត្តកម្រិតយោងព្រៃឈើជាតិ
- ការរៀបចំ និងការសាកល្បងអនុវត្តប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក។

បុព្វហេតុនៃការបាត់បង់ព្រៃឈើជាអាទិភាពដែលត្រូវដោះស្រាយក្នុងរយៈពេលនេះ គឺអាចដោះស្រាយបានតែតាមរយៈការពង្រឹងការអនុវត្តកម្មវិធីគ្រប់គ្រងព្រៃឈើដែលមានស្រាប់ប៉ុណ្ណោះ ដូចជា កម្មវិធីព្រៃឈើជាតិ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច។ ឯកសារទាំងនេះក៏មានរួមបញ្ចូលគោលនយោបាយ និងវិធានការនានា ដូចជា ការពង្រឹងការអនុវត្តច្បាប់

DRAFT

កំណែទម្រង់សិទ្ធិប្រើប្រាស់ដីធ្លី និងសហគ្រប់គ្រងការប្រើប្រាស់ដីព្រៃផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តគោលនយោបាយ និងវិធានការនានា ដូចមានចែងនៅក្នុងឯកសារទាំងនេះ នឹងអាចត្រូវពន្យារពេលដោយសារកង្វះខាតធនធានហិរញ្ញវត្ថុ និងសមត្ថភាពបច្ចេកទេស។ ប្រទេសកម្ពុជា នឹងអាចទទួលបានការទូទាត់ផ្អែកលើលទ្ធផលនៅពេលដែលកម្រិតយោងព្រៃឈើជាតិបឋមរបស់កម្ពុជា ត្រូវបានវាយតម្លៃបច្ចេកទេស យុទ្ធសាស្ត្ររេដបូកជាតិត្រូវបានបញ្ចប់ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូកត្រូវបានបង្កើតរួចរាល់។ នៅឆ្នាំ២០១៧ កម្ពុជានឹងអាចស្វែងរកការវិនិយោគហិរញ្ញវត្ថុបន្ថែម និងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ពីដៃគូអភិវឌ្ឍន៍ ដូចជា សហគមន៍អឺរ៉ុប និងកម្មវិធីវិនិយោគវិស័យព្រៃឈើរបស់ធនាគារពិភពលោក។ លើសពីនេះទៀត ដោយហេតុថា បុព្វហេតុនៃការបាត់បង់ព្រៃឈើជាអាទិភាពទាំងនេះ មានទំនាក់ទំនងជិតស្និទ្ធ និងស្ថិតក្រោមឥទ្ធិពលនៃបញ្ហាប្រឈមធំៗផ្សេងទៀត ដូចជា អភិបាលកិច្ចធនធានធម្មជាតិ កំណើនប្រជាជន និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ដូច្នេះយុទ្ធសាស្ត្ររេដបូកជាតិចាំបាច់ត្រូវកំណត់នូវគោលនយោបាយ និងវិធានការនានាដែលត្រូវធ្វើការដោះស្រាយនៅក្រៅវិស័យព្រៃឈើផងដែរ។ ដូច្នេះជាការចាំបាច់ មុខងារសម្របសម្រួលអន្តរក្រសួងរបស់ក្រុមការងាររេដបូកជាតិ ត្រូវបន្តមុនពេលមានយន្តការថ្មីមកជំនួស។

ផ្អែកតាមតម្រូវការចាំបាច់ផ្នែកបច្ចេកទេស ដើម្បីឲ្យកម្ពុជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចទទួលបានការទូទាត់ផ្អែកលើលទ្ធផលរេដបូកនៅឆ្នាំ២០២១ កម្ពុជាត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ កម្រិតយោងព្រៃឈើជាតិ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក ដែលអាចដំណើរការបានពេញលេញ ព្រមទាំងអាចគណនាបរិមាណនៃការបំភាយឧស្ម័នដែលបានកាត់បន្ថយតាមរយៈការអនុវត្តគោលនយោបាយ និងវិធានការរេដបូកដែលមានកំណត់នៅក្នុងផែនការសកម្មភាព ហើយស្របពេលជាមួយគ្នានេះ ធានាថាបានដោះស្រាយ និងគោរពលក្ខខ័ណ្ឌប្រព័ន្ធធានាសុវត្ថិភាពក្រុងកានគុណផងដែរ។

សម្រេចបានការងារនេះ សកម្មភាពដែលត្រូវអនុវត្តនៅមុនឆ្នាំ២០២០ រួមមាន៖

- រៀបចំគោលនយោបាយ បទដ្ឋាន និងយន្តការនានា ដែលទាក់ទងនឹងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ លទ្ធផលនៃសកម្មភាពដែលអាចធ្វើការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់បាន ដោយមានការអនុម័តពីក្រុមការងាររេដបូកជាតិ។ ឯកសារ និងយន្តការទាំងនេះ រួមបញ្ចូលទាំង ការសម្របសម្រួលស្ថាប័ន និងការចែករំលែកទិន្នន័យ ការធ្វើសុខដុម្មនីយកម្មទិន្នន័យ ការធានាគុណភាព និងវិធានការតាមដានត្រួតពិនិត្យ ការផ្តល់សុពលភាពលើការគណនាបរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានធ្វើឡើងនៅតាមកម្រិតខុសៗគ្នា ដែលរាប់ចាប់ពីទីតាំងនីមួយៗនៅតាមមូលដ្ឋាន រហូតដល់ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ
- ប្រមូលផ្តុំព័ត៌មានសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅកម្រិតជាតិ សម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដី ដើម្បីគណនាការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលជាលទ្ធផលនៃការអនុវត្តសកម្មភាពរេដបូកនៅកម្រិតជាតិ។ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ត្រូវរួមបញ្ចូលការបំភាយ និងការស្រូបឧស្ម័ន ដែលពាក់ព័ន្ធទាំងអស់នៅក្នុងសមត្ថកិច្ចប្រទេស
- បង្កើតទិន្នន័យ ដែលអាចភ្ជាប់នឹងគេហទំព័ររបស់លេខាធិការដ្ឋានអនុសញ្ញា UNFCCC សម្រាប់ការគ្រប់គ្រង និងដំណើរការទិន្នន័យភូមិសាស្ត្រ ព្រមទាំងបើកទូលាយដល់ការចូលប្រើប្រាស់សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍
- ចាត់ចែងឲ្យមានភាពបំពេញគ្នារវាងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក

DRAFT

- ប្រតិបត្តិការប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ដើម្បីធានាឲ្យមានទិន្នន័យសុក្រឹត អំពីបម្រែបម្រួលការប្រើប្រាស់ដីព្រៃ និងផលប៉ះពាល់មកលើសន្និធិកាបូន ព្រមទាំងមុខងារផ្សេងទៀតនៃប្រព័ន្ធអេកូឡូស៊ី
- ប្រមូលទិន្នន័យពាក់ព័ន្ធ និងរាយការណ៍ពីលទ្ធផល ដែលបានពីការអនុវត្តរេដបូក ទៅលេខាធិការដ្ឋានអនុសញ្ញា UNFCCC តាមរយៈឧបសម្ព័ន្ធបច្ចេកទេសដែលភ្ជាប់ជាមួយរបាយការណ៍បច្ចុប្បន្នភាពរយៈពេលពីរឆ្នាំម្តង
- កសាងសមត្ថភាពស្ថាប័នរេដបូកពាក់ព័ន្ធ។

ដំណាក់កាលទី២ ពីឆ្នាំ២០២១ - ២០២៥ (តំណាក់កាលទូទាត់ផ្អែកលើលទ្ធផលពីការអនុវត្តរេដបូក)

អនុលោមតាមគោលការណ៍នៃការអនុវត្តតាមអភិក្រមជាដំហាន ដូចបានកត់សម្គាល់ខាងលើ នៅដើមឆ្នាំ២០២១ វិធីសាស្ត្រ និងទិន្នន័យនៃប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ កម្រិតយោងព្រៃឈើជាតិ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក នឹងត្រូវបានកែលម្អរួចរាល់ ដូច្នេះយុទ្ធសាស្ត្ររេដបូកជាតិ នឹងពង្រីកការអនុវត្តសកម្មភាពដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើដទៃទៀត។ នៅក្នុងឆ្នាំ២០១៩ យុទ្ធសាស្ត្ររេដបូកជាតិ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ប្រព័ន្ធធានាសុវត្ថិភាពរេដបូក និងកម្រិតយោងព្រៃឈើជាតិ នឹងត្រូវបានធ្វើការវាយតម្លៃដោយឯករាជ្យ និងពេញលេញស្តីពីភាពខ្លាំង ភាពខ្សោយ ឱកាស និងឧបសគ្គ។ ទន្ទឹមនឹងនេះ ការពិគ្រោះយោបល់ពេញលេញ និងដោយប្រសិទ្ធភាព ជាមួយអ្នកពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេស ជាមួយតំណាងសហគមន៍មូលដ្ឋាន ក្រុមជនជាតិដើមភាគតិច និងក្រុមស្ត្រី អំពីបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ គោលនយោបាយ និងវិធានការរេដបូក ដែលនឹងត្រូវអនុវត្តបន្ថែមទៀត នៅក្នុងដំណាក់កាលនៃការទូទាត់ផ្អែកតាមលទ្ធផលពីការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ គឺជាកិច្ចការចាំបាច់ដែលត្រូវអនុវត្ត។

លើសពីនេះ ត្រូវធ្វើការសិក្សាបន្ថែមជាប្រចាំ អំពីបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ការគណនាបុព្វហេតុជាបរិមាណនៃការបំភាយកាបូន ការចាត់អាទិភាពបុព្វហេតុសំខាន់ៗ ដើម្បីដោះស្រាយនៅក្រោយឆ្នាំ២០២០ និងការវិភាគអំពីឱកាស និងឧបសគ្គពាក់ព័ន្ធនឹងនយោបាយ សង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា នៅក្នុងការដោះស្រាយបុព្វហេតុទាំងនេះ នៅក្នុងបរិបទ និងកម្រិតសមត្ថភាពរបស់ជាតិ។ ជាងនេះទៀត ដើម្បីធានាអនុលោមភាពជាមួយសេចក្តីសម្រេចនានាជាអន្តរជាតិស្តីពីរេដបូក ចាំបាច់ត្រូវធ្វើការសិក្សាឯកសារដែលមានស្រាប់អំពីគោលនយោបាយ សេចក្តីសម្រេច គោលការណ៍ណែនាំស្តីពីស្ថាប័ន ដូចជា UNFCCC និង IPCC ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។ កិច្ចការសំខាន់ គឺត្រូវតាមដានត្រួតពិនិត្យប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ នៃការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ដែលបានដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ តាមរយៈយន្តការទទួលយោបល់ឆ្លើយតបនៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក និងក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ វិធីសាស្ត្រ និងសកម្មភាពនានានៅទីវាល ចាំបាច់ត្រូវបន្តកែលម្អ និងអភិវឌ្ឍន៍បន្ថែមទៀត ដោយផ្អែកទៅតាមសេចក្តីត្រូវការមេរៀន និងបទពិសោធន៍ល្អៗ ហើយក៏ត្រូវប្រមូលកត់ត្រា និងចងក្រងទុកផងដែរ។

## ៦.២ ក្របខណ្ឌវ៉ស័រ (Warsaw) សម្រាប់រេដបូក

ដើម្បីមានសិទ្ធិគ្រប់គ្រាន់ ក្នុងការស្នើសុំការទូទាត់ផ្អែកលើលទ្ធផលសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវរៀបចំសមាសធាតុចំនួនបីផ្សេងទៀតឲ្យបានរួចរាល់ ស្របទៅតាមកិច្ចព្រមព្រៀងក្របខណ្ឌក្រុងវ៉ស័រ។ សមាសធាតុទាំងបីរួមមាន ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ កម្រិតយោងព្រៃឈើជាតិ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក។ ផ្នែកខាងក្រោមនេះ បង្ហាញពីស្ថានភាពបច្ចុប្បន្ន និងផែនការអនាគតសម្រាប់រៀបចំសមាសធាតុទាំងនេះ។

DRAFT

### ៦.២.១ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក (SIS)

យោងតាមសេចក្តីសម្រេចសន្និសីទភាគីនៃអនុសញ្ញា UNFCCC ដើម្បីឲ្យប្រទេសអនុវត្តរេដបូក អាចទទួលបានការទូទាត់ដោយផ្អែកលើលទ្ធផល ប្រទេសទាំងនោះចាំបាច់ត្រូវបង្កើតវិធីសាស្ត្រជាតិសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ដើម្បីលើកកម្ពស់ និងគាំទ្រដល់គោលការណ៍ប្រព័ន្ធធានាសុវត្ថិភាពរេដបូកទាំងប្រាំពីរនៃក្រុងកាន់គុណ ព្រមទាំងបង្កើតប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូកមួយសមស្របសម្រាប់ផ្តល់សេចក្តីសង្ខេបព័ត៌មានអំពីរបៀបឆ្លើយតប និងការគោរពតាមប្រព័ន្ធធានាសុវត្ថិភាពរេដបូកក្រុងកាន់គុណ នៅគ្រប់ពេលអនុវត្តគោលនយោបាយ និងវិធានការរេដបូក។ ការឆ្លើយតបបានតាមលក្ខខណ្ឌទាំងនេះ មិនត្រឹមតែអាចបង្កលទ្ធភាពឲ្យប្រទេសទាំងនោះទទួលបានការទូទាត់ផ្អែកលើលទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយដ៏សំខាន់ ដើម្បីកែលម្អ តម្លាភាព និងគណនេយ្យភាពនៅក្នុងការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិផងដែរ។ ប្រការនេះអាចបង្កើនឱកាសឲ្យប្រទេសអនុវត្តរេដបូក អាចទាក់ទាញការគាំទ្រហិរញ្ញវត្ថុ(ការវិនិយោគ)ជាមុន សម្រាប់គាំទ្រការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។

<u>ស្ថានភាពនៃសកម្មភាពរៀបចំប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក</u>

១. ការបង្កើតវិធីសាស្ត្រជាតិសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដបូកក្រុងកាន់គុណ

<u>គោលការណ៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដបូកនៅកម្ពុជា</u>

រាជរដ្ឋាភិបាល ប្រឹងប្រែងបង្កើតគោលការណ៍ និងលក្ខណៈវិនិច្ឆ័យធានាសុវត្ថិភាព ដោយបានគិតគូរ ដាក់បញ្ចូលពេញលេញនូវទស្សនវិស័យរបស់អ្នកពាក់ព័ន្ធ ទៅក្នុងវិធីសាស្ត្រប្រព័ន្ធធានាសុវត្ថិភាពរេដបូកជាតិ។ ទន្ទឹមនឹងនេះបានកំណត់ចំនួនគោលការណ៍ និងលក្ខណៈវិនិច្ឆ័យ ដើម្បីធ្វើឲ្យការតាមដានត្រួតពិនិត្យ និងការរៀបចំរបាយការណ៍មានលក្ខណៈជាក់ស្តែង និងអាចសម្រេចបាន។ អាស្រ័យហេតុនេះ សមត្ថកិច្ចរាជរដ្ឋាភិបាល បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយអ្នកពាក់ព័ន្ធសរុបចំនួន ៣១៧នាក់ មកពីស្ថាប័ន និងគ្រឹះស្ថានរដ្ឋាភិបាលពាក់ព័ន្ធ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច។ ការពិគ្រោះយោបល់ទូលំទូលាយទាំងនេះ បាននាំទៅដល់ការសម្រេចរៀបចំសំណើចុងក្រោយមួយ ដែលមានគោលការណ៍ចំនួន ៧ចំណុច និងលក្ខណៈវិនិច្ឆ័យចំនួន ១៤ ដែលផ្អែកជាសំខាន់លើប្រព័ន្ធសុវត្ថិភាពនៃទីក្រុងកាន់គុណ។ យោងតាមសំណូមពរពីការពិគ្រោះយោបល់ជាមួយក្រុមអ្នកពាក់ព័ន្ធ បានសម្រេចបញ្ចូលពាក្យ "ស្ត្រី" និង "សម្រាប់ព្រៃជាំ" ទៅក្នុងចំណុច (ង) និង (ច) នៃប្រព័ន្ធធានាសុវត្ថិភាពរេដបូកក្រុងកាន់គុណ។

<u>ការវិភាគភាពខ្វះចន្លោះក្នុងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា</u>

ស្របជាមួយដំណើរការពិគ្រោះយោបល់ទាំងនេះ ការវិភាគដំបូងមួយត្រូវបានធ្វើឡើង ដើម្បីកំណត់រកភាពខ្វះចន្លោះដែលអាចមាននៅក្នុងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់ និងសំណើគោលការណ៍ និងលក្ខណៈវិនិច្ឆ័យប្រព័ន្ធធានាសុវត្ថិភាពរេដបូកសម្រាប់កម្ពុជា។ ការងារនេះឆ្លើយតបនឹងសេចក្តីសម្រេចរបស់អនុសញ្ញា UNFCCC ដែលតម្រូវឲ្យប្រទេសអនុវត្តរេដបូក ផ្តល់សេចក្តីសង្ខេបព័ត៌មានអំពីរបៀបដែលប្រព័ន្ធធានាសុវត្ថិភាពរេដបូកក្រុងកាន់គុណ ត្រូវបានដោះស្រាយ។ លទ្ធផលនៃការវិភាគភាពខ្វះចន្លោះបឋមនេះបានសន្និដ្ឋានថា រាជរដ្ឋាភិបាលកម្ពុជា មានលិខិតបទដ្ឋានគោលនយោបាយ និងច្បាប់មួយចំនួន ដែលអាចដោះស្រាយសំណើគោលការណ៍ និងលក្ខណៈវិនិច្ឆ័យប្រព័ន្ធធានាសុវត្ថិភាពរេដបូកបាន ជាពិសេសសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពសង្គម។ ការវិភាគនេះក៏បានកំណត់នូវតម្រូវការសម្រាប់ពិចារណាបន្ថែមទៀតអំពីប្រព័ន្ធធានាសុវត្ថិភាពបរិស្ថាន ដើម្បីដោះស្រាយហានិភ័យនៃការវិលត្រឡប់មកស្ថានភាពដើម និងការលេចធ្លាយផងដែរ។

DRAFT

### ២. សំណើសូចនាករ និងប្រភពទិន្នន័យសម្រាប់ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក

ប្រទេសកម្ពុជា បានរៀបចំសំណើសេចក្តីព្រាងសូចនាករ និងប្រភពទិន្នន័យសម្រាប់តាមដានត្រួតពិនិត្យ និងរាយការណ៍អំពីថាតើប្រព័ន្ធធានាសុវត្ថិភាពរេដបូក ត្រូវបានដោះស្រាយ និងគោរពតាម បានដោយរបៀបណា នៅក្នុងការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ។ មានកិច្ចការបន្ថែមទៀតដែលត្រូវធ្វើការវាយតម្លៃអំពីប្រភេទព័ត៌មានដែលត្រូវប្រមូល និងការវិភាគសម្រាប់សូចនាករនីមួយៗ។

<u>ជំហាន ១ (ពីឆ្នាំ២០១៦-២០១៧)</u>

- បន្តអភិវឌ្ឍវិធីសាស្ត្រជាតិសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដបូក៖ កិច្ចការនេះទាមទារឲ្យមាន (១)ការកែសម្រួលគោលការណ៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដបូក (២)ការផ្សារភ្ជាប់គោលការណ៍ និងលក្ខណៈវិនិច្ឆ័យទាំងនេះជាមួយគោលនយោបាយ និងវិធានការរេដបូកជាក់លាក់ និង(៣)ការពិនិត្យពីលក្ខណៈច្បាប់នៃគោលការណ៍ និងលក្ខណៈវិនិច្ឆ័យដែលបានកែសម្រួល ដើម្បីធានាឲ្យមានសង្គតិភាពជាមួយច្បាប់របស់កម្ពុជា
- បង្កើតជម្រើសសមស្របសម្រាប់ក្របខណ្ឌប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក៖ កិច្ចការនេះទាក់ទងនឹង (១) សំណើឲ្យមានសូចនាករ ប្រភពទិន្នន័យ និងវិធីប្រមូលទិន្នន័យ អំពីលទ្ធភាព និងភាពជាក់ស្តែងនៃការអនុវត្ត និង (២)ការកំណត់រចនាសម្ព័ន្ធ(ដែលមានស្រាប់ និង/ឬបង្កើតថ្មី) និងយន្តការសម្របសម្រួល ដើម្បីប្រមូល វិភាគ តាមដាន រៀបចំទុកដាក់ និងរាយការណ៍ ផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធធានាសុវត្ថិភាពរេដបូក ចាប់ពីថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ រហូតថ្នាក់អន្តរជាតិ និងផ្ទុយមកវិញ។ សំណើទាំងនេះនឹងត្រូវរៀបចំឡើង ក្រោមការសម្របសម្រួលជិតស្និទ្ធជាមួយព័ត៌មាននៃការវាស់វែង រាយការណ៍ និងការផ្ទៀងផ្ទាត់ សារពើភ័ណ្ឌព្រៃឈើជាតិ ប្រព័ន្ធត្រួតពិនិត្យតាមដានព្រៃឈើជាតិ និងក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

<u>ជំហាន ២ (ពីឆ្នាំ២០១៨ ដល់ ២០២០)</u>

- ការបង្កើតយន្តការដោះស្រាយទំនាស់រេដបូក៖ នៅក្នុងករណីមានការរំលោភលើប្រព័ន្ធធានាសុវត្ថិភាពរេដបូក សមត្ថកិច្ចរាជរដ្ឋាភិបាល នឹងចាត់វិធានការសមស្រប និងជាបន្ទាន់ ដើម្បីធានាថាសកម្មភាពនោះ អនុវត្តបានត្រឹមត្រូវ ឆ្លើយតបតាមប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូកដែលបានកំណត់។ ក្នុងន័យនេះ រាជរដ្ឋាភិបាល គ្រោងកំណត់ និងបន្តកែលម្អប្រើប្រាស់រចនាសម្ព័ន្ធ និងយន្តការនានាដែលមានស្រាប់ដើម្បីដោះស្រាយទំនាស់ដែលទាក់ទងនឹងរេដបូក
- ការផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធដែលទទួលបន្ទុកការងារប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក
- ធានាឲ្យមានធនធានហិរញ្ញវត្ថុសម្រាប់ចាប់ផ្តើមអនុវត្តសាកល្បងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក និងចងក្រងលទ្ធផល សម្រាប់រៀបចំប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូកចុងក្រោយ
- ប្រមូល និងវិភាគលទ្ធផលនៃការអនុវត្តប្រព័ន្ធធានាសុវត្ថិភាពរេដបូក រួមទាំងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូកពីបណ្តាក្រសួងពាក់ព័ន្ធ។

<u>ជំហាន ៣ (ក្រោយឆ្នាំ២០២០ តទៅ)</u>

- ពិនិត្យ និងកែសម្រួលប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូកជាប្រចាំ រួមទាំងការរៀបចំរចនាសម្ព័ន្ធ

DRAFT

- ស្វែងរកដំណោះស្រាយដែលអាចមាន ដើម្បីកែលម្អប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក តាមច្បាប់ បទប្បញ្ញត្តិនានា គោលនយោបាយ និងគោលការណ៍ លក្ខណៈវិនិច្ឆ័យ និងសូចនាករណ៍
- លើកសំណើកែសម្រួល គោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងរៀបចំសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិថ្មីៗសម្រាប់រេដបូកប្រសិនបើចាំបាច់
- ធានាឲ្យមានធនធានមនុស្ស និងហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូករយៈពេលវែង។

### ៦.២.២ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ( NFMS )

ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ត្រូវបានរំពឹងថាអាចផ្តល់ពត៌មានពាក់ពន្ធ័នឹងការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់សកម្មភាពរេដបូក និងគាំទ្រដល់គោលនយោបាយខាងវិស័យព្រៃឈើនិងកម្មវិធីនានា ដូចជាកម្មវិធីព្រៃឈើជាតិ ផែនការយុទ្ធសាស្រ្តជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ និងក្របខណ្ឌផែនការយុទ្ធសាស្រ្តសម្រាប់វិស័យជលផល។ កម្ពុជាបានតាមដានត្រួតពិនិត្យរបាយតំបន់ព្រៃឈើ តាមរយៈការផលិតផែនទីដោយប្រើប្រាស់រូបភាពផ្កាយរណប។ បន្ថែមលើនេះ កម្ពុជា ក៏បានធ្វើការសិក្សាស្រាវជ្រាវការធ្វើសារពើភ័ណ្ឌព្រៃឈើ លើប្រភេទព្រៃឈើផ្សេងៗគ្នាផងដែរ។ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ មានមុខងារសំខាន់ពីរ គឺមុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ និងមុខងារតាមដានត្រួតពិនិត្យ។ មុខងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ គឺសម្រាប់រាយការណ៍អំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ហើយបែងចែកចេញជាបីសមាសធាតុរួមមាន ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។ ការវាស់វែង មានរួមបញ្ចូលទាំងការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ប្រព័ន្ធតាមដានត្រួតពិនិត្យស្ថានភាពគម្របដីពីផ្កាយរណប និងសារពើភ័ណ្ឌព្រៃឈើជាតិ។

<u>ដំណើរការផ្ទៀងផ្ទាត់មានពីរតំណាក់កាល</u>

ដំណាក់កាលដំបូង គឺការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ផ្ទៃក្នុង ដោយក្រុមការងារបច្ចេកទេសការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) រួចដាក់លទ្ធផលជូនថ្នាក់ដឹកនាំពិនិត្យសម្រេច និងដំណាក់កាលបន្ទាប់ គឺការផ្ទៀងផ្ទាត់ និងវាយតម្លៃដោយយន្តការ UNFCCC ។ ការតាមដានត្រួតពិនិត្យ គឺបូករួមទាំងការតាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃគោលនយោបាយ និងវិធានការរេដបូក ក្នុងការដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ ព្រមទាំងការប្រមូល ការទុកដាក់ វិភាគ និងផ្សព្វផ្សាយទិន្នន័យពាក់ព័ន្ធ។ ប្រព័ន្ធតាមដានត្រួតពិនិត្យគម្របដីពីផ្កាយរណប ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងមុខងារតាមដានត្រួតពិនិត្យផងដែរ ដោយផ្តល់ពត៌មានជាប្រចាំអំពីស្ថានភាពនៃការប្រើប្រាស់ដី និងគម្របដី។ ដំណាក់កាលចុងក្រោយ ព័ត៌មានដែលត្រូវបានប្រមូលដោយប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ជាពិសេស តាមរយៈមុខងារតាមដានត្រួតពិនិត្យ ក៏នឹងត្រូវបានកំណត់តំណាលគ្នានឹងការរៀបចំក្របខណ្ឌប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក និងក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃផងដែរ។

<u>ស្ថានភាពនៃសកម្មភាពរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ</u>

១. ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS)

- **ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ** ត្រូវបានបង្កើតឡើង ដោយផ្តោតលើការតាមដានត្រួតពិនិត្យបម្រែបម្រួលគម្របដីព្រៃឈើ ដែលមានចំណាត់ថ្នាក់ប្រើប្រាស់ដី/ចំណាត់ថ្នាក់គម្របដី ចំនួន ៦ប្រភេទ (យោងតាមការណែនាំរបស់ IPCC ឆ្នាំ២០០៦) ពោលគឺ ដីព្រៃឈើ ដីដាំដំណាំ ដីវាលស្មៅ ដីតាំងទីលំនៅ ដីផ្សេងទៀត និងដីសើម ជាពិសេសការប្រែប្រួលពីតំបន់ព្រៃឈើ ទៅជាតំបន់មិនមែនព្រៃឈើ ហើយក៏តាមដានត្រួតពិនិត្យផងដែរ លើប្រសិទ្ធភាព និងលទ្ធផលនៃការអនុវត្តគោលនយោបាយ និងវិធានការរេដបូក

DRAFT

- **ការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ** បានកសាងរួចរាល់
- **វិធីសាស្ត្រតាមដានត្រួតពិនិត្យ** ត្រូវកំណត់ឲ្យបានស្របតាមគោលនយោបាយ និងវិធានការរេដបូក ដែលនឹងត្រូវជ្រើសរើសយកមកអនុវត្ត
- **ប្រព័ន្ធគ្រប់គ្រងកម្រងទិន្នន័យ** ត្រូវបានបង្កើតឡើង ដើម្បីរក្សាទុក និងគ្រប់គ្រងទិន្នន័យ និងព័ត៌មានដែលចាំបាច់សម្រាប់ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងធានាថា អ្នកពាក់ព័ន្ធទាំងអស់អាចប្រើប្រាស់ទិន្នន័យ និងព័ត៌មានពាក់ព័ន្ធសម្រាប់ការអនុវត្តសកម្មភាពរេដបូកបាន
- **គេហទំព័រ** (WEB-Portal) កំពុងត្រូវបានរៀបចំ ជាមួយគ្នានេះ ឧបករណ៍ស្តុកមូលដ្ឋានទិន្នន័យ ក៏កំពុងរៀបចំឡើងផងដែរ ដើម្បីធានាដល់ការចែករំលែកទិន្នន័យដែលទាក់ទងនឹងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិប្រកបដោយតម្លាភាព។

## ២. ប្រព័ន្ធតាមដានត្រួតពិនិត្យស្ថានភាពគម្របដីពីផ្កាយរណប

- រៀងរាល់បួនឆ្នាំម្តង ដោយគិតចាប់តាំងពីឆ្នាំ២០០២មក រដ្ឋបាលព្រៃឈើបានផលិតផែនទីគម្របព្រៃឈើជាតិដោយប្រើប្រាស់រូបភាពពីផ្កាយរណប និងបានប្រើប្រាស់ផែនទីនេះសម្រាប់ការអភិវឌ្ឍ ការគ្រប់គ្រង និងការអភិរក្សព្រៃឈើ។ ថ្មីៗនេះ ផែនទីគម្របព្រៃឈើជាតិឆ្នាំ២០០៦ និងឆ្នាំ២០១០ ត្រូវបានកែលម្អ ដោយកែប្រែចំណាត់ថ្នាក់នៃការប្រើប្រាស់ដី/ចំណាត់ថ្នាក់គម្របព្រៃឈើ ដើម្បីធ្វើសុខដុមនីយកម្មជាមួយចំណាត់ថ្នាក់ប្រើប្រាស់ដីទាំង៦ប្រភេទ ដែលកំណត់ដោយ IPCC ឆ្នាំ២០០៦ ។ លើសពីនេះទៀត ផែនទីគម្របព្រៃឈើជាតិឆ្នាំ២០១៤ ត្រូវបានផលិតដោយប្រើប្រាស់ជំពូកនៃការប្រើប្រាស់ដី/ចំណាត់ថ្នាក់គម្របព្រៃឈើ ដូចគ្នានឹងចំណាត់ថ្នាក់សម្រាប់ ឆ្នាំ២០០៦ និង២០១០ ផងដែរ
- រូបភាពផ្កាយរណប នឹងត្រូវបន្តប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការបង្កើតផែនទីគម្របព្រៃឈើ ដោយសារមានប្រសិទ្ធភាពខាងថ្លៃចំណាយ និងមានភាពងាយស្រួលក្នុងការកំណត់ពីការប្រែប្រួលការប្រើប្រាស់ដី
- វិធីសាស្ត្រគូសព្រំប្រទល់នៃចំណាត់ថ្នាក់គម្របព្រៃឈើ (ដោយប្រើរូបភាពផ្កាយរណប) ដែលបានប្រើប្រាស់នាឆ្នាំ២០១៣ និងបានផលិតផែនទីគម្របព្រៃឈើជាតិឆ្នាំ២០១៤ ព្រមទាំងយកមកប្រើប្រាស់ឲ្យមានសង្គតិភាពរវាងផែនទីគម្របព្រៃឈើឆ្នាំ២០០៦ ២០១០ ជាមួយនឹងឆ្នាំ២០១៤
- នៅក្នុងការធ្វើកំណែផែនទីឆ្នាំ២០០៦ និងឆ្នាំ២០១០ និងក្នុងការបង្កើតផែនទីឆ្នាំ២០១៤ ការប្រើប្រាស់ដី/ចំណាត់ថ្នាក់ព្រៃឈើស្របតាមគោលការណ៍ណែនាំរបស់IPCCឆ្នាំ២០០៦
- ព័ត៌មានផ្សេងទៀតពីផ្កាយរណប ដូចជាព័ត៌មានដែលបានផ្តល់តាមប្រព័ន្ធ Google Earth ក៏ត្រូវបានយកមកប្រើប្រាស់ផងដែរសម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។

## ៣. សារពើភ័ណ្ឌព្រៃឈើជាតិ (NFI)

- នៅពុំទាន់បានធ្វើសារពើភ័ណ្ឌព្រៃឈើ ជាលក្ខណៈប្រព័ន្ធគ្របដណ្តប់លើតំបន់ព្រៃឈើទាំងមូលក្នុងប្រទេសនៅឡើយទេ។ សៀវភៅណែនាំស្តីពីការងារបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើជាតិ បានបង្កើតឡើងដោយរដ្ឋបាលព្រៃឈើ សម្រាប់ធ្វើការប៉ាន់ប្រមាណបរិមាណឈើ (ឈើឈរ ឈើងាប់ និងកំទេចកំទីឈើនៅលើដី) ឬសម្រាប់ការស្រាវជ្រាវដោយអ្នកស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ
- ការរៀបចំសារពើភ័ណ្ឌព្រៃឈើជាតិ និងសៀវភៅណែនាំស្តីពីការងារបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើជាតិ នៅទីវាល បានចងក្រង និងត្រូវបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៦

DRAFT

- ចំពោះការរៀបចំស្ថាប័ន រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងក្រសួងបរិស្ថាន មានភារៈកិច្ចទទួលខុសត្រូវលើការងាររៀបចំសារពើភ័ណ្ឌព្រៃឈើជាតិ ទៅតាមដែនសមត្ថកិច្ចរៀងៗខ្លួន ដែលក្នុងនោះរួមបញ្ចូលទាំងការវិភាគនៅក្នុងមន្ទីរពិសោធន៍ផងដែរក្នុងពេលចាំបាច់។ លទ្ធផលបានមកពីការងារធ្វើសារពើភ័ណ្ឌព្រៃឈើជាតិនឹងត្រូវរក្សាទុកដោយសមាជិកក្រុមការងារបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់
- ទិន្នន័យអំពីជីវម៉ាស់ដើមឈើ ត្រូវបានវិភាគ ហើយមេគុណបំភាយ ត្រូវបានកំណត់សម្រាប់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃដុះឡើងវិញ ព្រៃលិចទឹក ចម្ការឈើ ព្រៃកោងកាង និងព្រៃឫស្សី ដែលត្រូវបានប្រើប្រាស់សម្រាប់ការគណនាកម្រិតយោងព្រៃឈើជាតិ។

៤. សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

- ដំណើរការចងក្រងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជាដែលបំភាយចេញពីការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដី និងវិស័យព្រៃឈើ ត្រូវបានពិនិត្យ និងសិក្សាដោយក្រុមការងារបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។ លើសពីនេះក្រុមការងារបច្ចេកទេសនេះ ក៏បានផ្តល់ការបណ្តុះបណ្តាលអំពីរបៀបនៃការប្រើប្រាស់ឧបករណ៍ផ្នែកទន់សម្រាប់គណនាការបំភាយឧស្ម័នផ្ទះកញ្ចក់ផងដែរ
- វិធីដែលនឹងត្រូវយកមកប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍បច្ចេកទេសរយៈពីរឆ្នាំម្តង (BUR) និងរបាយការណ៍ជាតិនាពេលខាងមុខ នៅពុំទាន់បានកំណត់នៅឡើយទេ។

<u>ផែនការរយៈពេលមធ្យម (ឆ្នាំ២០១៦-២០២០)</u>

១. ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS)

- ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ នឹងត្រូវបង្កើតឡើង អនុលោមតាមអភិក្រមជាជំហាន ស្របជាមួយនឹងការអភិវឌ្ឍបច្ចេកវិទ្យា និងការអភិវឌ្ឍសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅពេលអនាគត ដែលទទួលខុសត្រូវប្រតិបត្តិការប្រព័ន្ធនេះ
- យន្តការតាមដានការអនុវត្តគោលនយោបាយ និងវិធានការរេដបូក នឹងត្រូវរៀបចំឡើង (បន្ថែមពីលើព័ត៌មានដែលបានប្រមូលដោយប្រព័ន្ធតាមដានត្រួតពិនិត្យស្ថានភាពគម្របដីពីផ្កាយរណប សារពើភ័ណ្ឌព្រៃឈើជាតិ និងយន្តការប្រមូលព័ត៌មានដែលមានស្រាប់របស់រាជរដ្ឋាភិបាលកម្ពុជា)។

២. ប្រព័ន្ធតាមដានត្រួតពិនិត្យស្ថានភាពគម្របដីពីផ្កាយរណប

- ផែនទីគម្របព្រៃឈើសម្រាប់ឆ្នាំ២០១៦ ត្រូវបានផលិត និងបន្តធ្វើបច្ចុប្បន្នកម្មរៀងរាល់ ២ ឆ្នាំម្តង
- បង្កើតវិធីសាស្ត្រដើម្បីកំណត់ទីតាំងតំបន់ព្រៃរេចរិល ដោយពុំចាំបាច់ធ្វើសារពើភ័ណ្ឌព្រៃឈើជាតិឡើងវិញ
- ការកសាងសមត្ថភាពមន្ត្រីជំនាញ អំពីជំនាញក្នុងការបកស្រាយរូបភាពផ្កាយរណប។

៣. សារពើភ័ណ្ឌព្រៃឈើជាតិ (NFI)

- ចាប់ផ្តើមអនុវត្តសារពើភ័ណ្ឌព្រៃឈើជាតិ នៅក្នុងតំបន់ឡូត៍អចិន្ត្រៃយ៍
- ពិនិត្យលទ្ធផលបឋមនៃការអនុវត្តសារពើភ័ណ្ឌព្រៃឈើជាតិ និងធ្វើការកែសម្រួល ក្នុងករណីចាំបាច់
- ការអនុវត្តសារពើភ័ណ្ឌព្រៃឈើជាតិ ក្នុងកម្រិតពេញលេញ
- ពិនិត្យមើលលើការរៀបចំសារពើភ័ណ្ឌព្រៃឈើជាតិ និងការកែសម្រួលសម្រាប់ការអនុវត្តនៅជុំទីពីរ។

៤. សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

- ការរៀបចំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ សម្រាប់រៀបចំរបាយការណ៍ជាតិលើកទីបី និងរបាយការណ៍រយៈពេលពីរឆ្នាំម្តងលើកដំបូងរបស់កម្ពុជា
- មានការរំពឹងថា របាយការណ៍រយៈពេលពីរឆ្នាំម្តងលើកដំបូងរបស់កម្ពុជា នឹងត្រូវដាក់ជូនអនុសញ្ញា UNFCCC នៅឆ្នាំ២០១៨
- ការជ្រើសរើសវិធីសមស្របមួយ - វិធីកើន-ថយ ឬ វិធីភាពខុសគ្នានៃស្តុកកាបូន
- ការជ្រើសរើសប្រើប្រាស់គោលការណ៍ណែនាំរបស់ IPCC ឆ្នាំ២០០៦។

## ៦.២.៣ កម្រិតយោងព្រៃឈើ ( FREL/FRL )

កម្រិតយោងព្រៃឈើ គឺជាលក្ខខ័ណ្ឌគោលសម្រាប់វាយតម្លៃស្ថានភាពប្រទេសក្នុងការអនុវត្តគោលនយោបាយ និងវិធានការរេដបូក និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ប្រទេសកំពុងអភិវឌ្ឍន៍ ដែលចង់ទទួលបានការទូទាត់ផ្អែកលើលទ្ធផលសម្រាប់សកម្មភាពរេដបូក ត្រូវដាក់ជូនសំណើកម្រិតយោងព្រៃឈើរបស់ខ្លួនទៅអនុសញ្ញា UNFCCC សម្រាប់ការវាយតម្លៃបច្ចេកទេស។ គោលបំណងនៃការវាយតម្លៃបច្ចេកទេស គឺដើម្បីធ្វើការវាយតម្លៃអំពីកម្រិតដែលព័ត៌មានពិស្តារនៅក្នុងឯកសារសំណើកម្រិតយោងព្រៃឈើ ឆ្លើយតបនឹងគោលការណ៍ណែនាំក្រោមអនុសញ្ញា UNFCCC និងផ្តល់យោបល់ផ្លាស់ប្តូរព័ត៌មានបច្ចេកទេសអំពីការបង្កើតកម្រិតយោងព្រៃឈើ ។

កម្រិតយោងព្រៃឈើ អាចធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលកំណត់មួយ ដើម្បីឆ្លុះបញ្ចាំងពីការកែលម្អទិន្នន័យ សមត្ថភាព និង/ឬ ការប្រែប្រួលនៃកាលៈទេសៈរបស់ជាតិ ទំហំ ឬ វិធីសាស្ត្រ។ ដោយសារតែដំណើរការវាយតម្លៃបច្ចេកទេសអនុញ្ញាតឲ្យមានការផ្លាស់ប្តូរព័ត៌មានបច្ចេកទេស ដំណើរការនេះត្រូវបានគេចាត់ទុកថានឹងអាចផ្តល់សេចក្តីណែនាំពីការកែលម្អបច្ចេកទេសកម្រិតយោងព្រៃឈើនៅពេលអនាគត។ នៅពេលដែលកម្រិតយោងព្រៃឈើ បានឆ្លងកាត់ការវាយតម្លៃបច្ចេកទេសរួចហើយ ប្រទេសកំពុងអភិវឌ្ឍន៍ដែលចង់បានការទូទាត់ផ្អែកលើលទ្ធផលពីការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ត្រូវភ្ជាប់ឧបសម្ព័ន្ធបច្ចេកទេស ជាមួយនឹងរបាយការណ៍រយៈពេលពីរឆ្នាំម្តងរបស់ខ្លួន។ របាយការណ៍រយៈពេលពីរឆ្នាំម្តងនេះ នឹងរួមបញ្ចូលទាំងរបាយការណ៍សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ ដែលនឹងក្លាយជាកម្មវត្ថុនៃការពិគ្រោះយោបល់ និងការវិភាគជាអន្តរជាតិ ព្រមទាំងការវិភាគអំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ក៏ដូចជាឥទ្ធិពលនៃសកម្មភាពកាត់បន្ថយការបំភាយឧស្ម័នផងដែរ។

<u>ស្ថានភាពនៃសកម្មភាពរៀបចំកម្រិតយោងព្រៃឈើ</u>

១. ការប្រឈម និងឧបសគ្គ

របាយការណ៍បឋមស្តីពីកម្រិតយោងព្រៃឈើ បានរៀបចំបញ្ចប់ដោយអនុលោមតាមវិធីសាស្ត្រ និងអភិក្រមជាជំហាន។ នៅដំណាក់កាលដំបូង កម្រិតយោងព្រៃឈើកម្ពុជា ផ្តោតសំខាន់លើ វិសាលភាព គោលនយោបាយ និងវិធានការរេដបូក ក្នុងកម្រិតកំណត់មួយ។ វិធីប៉ាន់ប្រមាណឲ្យប្រសើរជាងមុន គ្រោងនឹងដាក់បញ្ចូលទៅក្នុងការរៀបចំកម្រិតយោងព្រៃឈើ ជាតំណាក់កាលបន្តបន្ទាប់ នៅពេលមានទិន្នន័យ និងមានវិធីថ្មីៗ ត្រូវបានរៀបចំឡើង។

២. ស្ថានភាពបច្ចុប្បន្ននៃការរៀបចំកម្រិតយោងព្រៃឈើ

- **អាងសន្និធិកាបូន និងឧស្ម័នផ្ទះកញ្ចក់៖** នឹងវាយតម្លៃ ការបំភាយឧស្ម័នកាបូនិក (CO2) ដែលជាសមាសធាតុមួយនៃឧស្ម័នផ្ទះកញ្ចក់ និងអាងស្តុកជីវម៉ាស់លើដី និងក្រោមដីនៅក្នុងតំបន់ព្រៃឈើ
- **កម្រិត៖** កម្រិតយោងព្រៃឈើ (កម្រិតជាតិ)

- **វិសាលភាព៖** ការបាត់បង់ព្រៃឈើ និងការដាំដើមឈើនៅតំបន់ដែលគ្មានព្រៃឈើ
- **រយៈពេលយោង៖** ឆ្នាំ២០០៦-២០១៤
- **វិធីសាស្ត្រ៖** ជាមធ្យម ៨ ឆ្នាំរំកិល
- **ទិន្នន័យសកម្មភាព៖** ការអង្កេតមើលជាក់ស្តែងនៅទីវាលលើជំពូកនានានៃការប្រើប្រាស់ និងការបម្លែងដី ចន្លោះឆ្នាំ២០០៦ ឆ្នាំ២០១០ និងឆ្នាំ២០១៤។ ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត ត្រូវបានញែកចេញពីគ្នាអាស្រ័យតាមប្រភេទដី។ វដ្តនៃការធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីនឹងធ្វើរៀងរាល់ ៤ឆ្នាំម្តង
- **មេគុណបំភាយ៖** មេគុណបំភាយជាក់លាក់នៃប្រទេសណាមួយសម្រាប់ជំពូកសំខាន់ៗ (លំដាប់ទី២) ដោយផ្អែកលើទិន្នន័យសារពើភ័ណ្ឌព្រៃឈើដែលមានស្រាប់ ដោយមានជំនួយមេគុណបំភាយជំនួស សម្រាប់ជំពូកដទៃទៀត
- **វិធីបង្កើតកម្រិតយោងព្រៃឈើ៖** ប្រវត្តិកាលតួលេខមធ្យមភាគរួមជាមួយការពិនិត្យមើលកាលៈទេសៈរបស់ជាតិ។

កម្ពុជាកំពុងគ្រោងដាក់កម្រិតយោងព្រៃឈើដំបូងរបស់ខ្លួន ទៅអនុសញ្ញា UNFCCC សម្រាប់ការវាយតម្លៃបច្ចេកទេស នៅខែមករា ឆ្នាំ២០១៧។

### ៣. ផែនការអនាគត

ផែនការដើម្បីដោះស្រាយការប្រឈម និងឧបសគ្គ ដែលបានកត់សម្គាល់ខាងលើ ដែលផ្តោតលើលទ្ធផលដោយបានព្យាករណ៍ និងលទ្ធផលសម្រេចបានពីការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។ កម្រិតយោងព្រៃឈើ នឹងត្រូវពិនិត្យកែសម្រួលទៅតាមពេលវេលាកំណត់ជាក់លាក់ បន្ទាប់ពីបានដាក់បញ្ចូលទិន្នន័យ និន្នាការ និងវិធីសាស្ត្រថ្មីៗបន្ថែមទៀត។ ផ្នែកទាំងឡាយដែលត្រូវពិនិត្យឡើងវិញ ក្នុងពេលដ៏ខ្លីខាងមុខ នៅក្នុងរយៈពេលជាមធ្យមរួមមាន៖

- **អាងស្តុកកាបូន និងឧស្ម័ន៖** ការរួមបញ្ចូលឈើងាប់ កម្ទេចកំទី និងសារធាតុសរីរាង្គដី ក្នុងករណីសមស្រប
- **មេគុណបំភាយ៖** ការរួមបញ្ចូល ឬការកែលម្អមេគុណបំភាយដែលមានស្រាប់ ទៅតាមករណីសមស្រប
- **វិសាលភាព៖** ការកែសម្រួលវិសាលភាព ទៅតាមករណីសមស្រប
- **វិធីសាស្ត្របង្កើតកម្រិតយោងព្រៃឈើ៖** ប្រសិនបើប្រមូលបានទិន្នន័យសកម្មភាពគ្រប់គ្រាន់ និន្នាការជាប្រវត្តិកាលកន្លងមកនឹងត្រូវយកមកវិភាគ ទៅតាមករណីសមស្រប
- **រយៈពេលយោង៖** ប្រសិនបើបានប្រមូលទិន្នន័យសកម្មភាពគ្រប់គ្រាន់ ហើយកាលៈទេសៈរបស់ជាតិតម្រូវឲ្យមានការពិនិត្យឡើងវិញ អំឡុងពេលយោងនឹងត្រូវកែសម្រួល តាមករណីសមស្រប
- **វដ្តនៃការធ្វើបច្ចុប្បន្នភាព៖** កាលបរិច្ឆេទនៃការធ្វើបច្ចុប្បន្នភាពកម្រិតយោងព្រៃឈើ គឺអាស្រ័យលើលទ្ធផលនៃការវាយតម្លៃបច្ចេកទេសនៃការអនុវត្តកម្រិតយោងព្រៃឈើ និងទិន្នន័យថ្មីៗនាពេលបច្ចុប្បន្ន។ ការរួមបញ្ចូលទិន្នន័យសកម្មភាពថ្មីៗ (ឆ្នាំ២០១៦ ឆ្នាំ២០១៨ និងឆ្នាំ២០២០) ការចងក្រងសារពើភ័ណ្ឌព្រៃឈើជាតិ (ឆ្នាំ ២០១៦-២០២០) គឺជាចំណុចគោលចម្បង
- **ដំណាក់កាលបន្ទាប់៖** កម្រិតយោងព្រៃឈើ នឹងគណនាការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ សម្រាប់រយៈពេលពី ឆ្នាំ២០១០ ដល់ ២០១៨
- **ដំណាក់កាលចុងបញ្ចប់៖** រាជរដ្ឋាភិបាលមានគោលដៅ ផលិតទិន្នន័យប្រចាំឆ្នាំ ដើម្បីលើកកម្ពស់ភាពត្រឹមត្រូវនៃកម្រិតយោងព្រៃឈើឲ្យកាន់តែប្រសើរឡើង។

DRAFT

## ៦.៣ ការរៀបចំយន្តការ និងការសម្របសម្រួល

ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ នឹងអនុលោមស្របទៅតាមដែនសមត្ថកិច្ចរបស់ស្ថាប័នរដ្ឋាភិបាល ហើយស្ថាប័នទាំងនេះនឹងរួមចំណែកក្នុងការរៀបចំផែនការសកម្មភាពរេដបូក ទៅតាមដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមច្បាប់ និងគោលនយោបាយដែលមានជាធរមាន។ ការអនុវត្តនឹងត្រូវផ្អែកលើក្របខណ្ឌជាតិ ដោយសាររេដបូកតម្រូវឲ្យធ្វើការអនុវត្តនៅកម្រិតជាតិ នឹងត្រូវរៀបចំរបាយការណ៍ជាតិសម្រាប់ដាក់ជូន UNFCCC។

### ៦.៣.១ ការរៀបចំរចនាសម្ព័ន្ធដែលមានស្រាប់ សម្រាប់ពិនិត្យមើលការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ

**ក្រុមការងាររេដបូកជាតិ** មានតំណាងចំនួន១០រូបមកពីក្រសួងចំនួនប្រាំពីរ ដែលមានអាណត្តិគ្រប់គ្រងការរៀបចំដំណាក់កាលត្រៀមរេដបូក។ ក្រសួងទាំងប្រាំពីរដែលមានតំណាងនៅក្នុងក្រុមការងាររេដបូកជាតិរួមមាន៖ (១)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២)ក្រសួងបរិស្ថាន (៣)ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (៤)ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ (៥)ក្រសួងមហាផ្ទៃ (៦)ក្រសួងអភិវឌ្ឍន៍ជនបទ និង (៧)ក្រសួងរ៉ែ និងថាមពល។ ការទទួលខុសត្រូវរបស់ក្រុមការងារជាតិ គឺគ្រប់គ្រងកម្មវិធីរេដបូកជាតិ សម្របសម្រួលការអនុវត្តគោលនយោបាយ និងវិធានការរេដបូកនៅថ្នាក់ជាតិ ជានាថាការឆ្លើយតបរបស់រដ្ឋាភិបាល មានការសម្របសម្រួលបានល្អ និងបានបញ្ជ្រាបរេដបូកទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ជាតិ។

**ក្រុមបច្ចេកទេសរេដបូកចំនួន៤** ដែលបានបង្កើតឡើងដោយក្រុមការងាររេដបូកជាតិ មានភារៈកិច្ចទទួលខុសត្រូវលើការផ្តល់អនុសាសន៍ លើបញ្ហាបច្ចេកទេសសំខាន់ៗ។ ក្រុមបច្ចេកទេសទាំងបួននេះគឺ៖ (១)ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាព (២)ក្រុមបច្ចេកទេសបែងចែកផលប្រយោជន៍ (៣)ក្រុមបច្ចេកទេសអនុវត្តគម្រោងគំរូ (៤)ក្រុមបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។ សមាជិកក្រុមបច្ចេកទេសទាំងនេះរួមមាន មន្ត្រីបច្ចេកទេសមកពីស្ថាប័នពាក់ព័ន្ធផ្សេងៗ ដែលមានតួនាទីទទួលខុសត្រូវលើការពិភាក្សាអំពីបញ្ហាបច្ចេកទេស។ ក្រុមបច្ចេកទេសទាំងនេះក៏មានសមាជិក ដែលជាតំណាងមកពីសង្គមស៊ីវិល ក្រុមជនជាតិដើមភាគតិច និងអង្គការក្រៅរដ្ឋាភិបាល ដែលបានជ្រើសរើសក្នុងចំណោមសមាជិកក្រុមប្រឹក្សាយោបល់រេដបូកផងដែរ។

**ក្រុមប្រឹក្សាយោបល់រេដបូក** តំណាងដោយសមាជិកពីររូបដែលបានពីការបោះឆ្នោតជ្រើសរើសចេញមកពីស្ថាប័នចំនួនប្រាំបួននៅកម្ពុជា។ ស្ថាប័នទាំងប្រាំបួននេះរួមមាន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន ក្រុមជនជាតិដើមភាគតិច សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឯកជន។ ក្រុមការងាររេដបូកជាតិ បញ្ជូនរបាយការណ៍ និងការសម្រេចនានា ព្រមទាំងសេចក្តីព្រាងផែនការយុទ្ធសាស្ត្ររេដបូកជាតិ ទៅឲ្យក្រុមប្រឹក្សាយោបល់រេដបូក ដើម្បីផ្តល់យោបល់ ក៏ដូចជាឆ្លើយតបចំពោះយោបល់ដែលបានលើកឡើងដោយសមាជិកក្រុមរបស់ខ្លួន។

**ក្រុមយេនឌ័ររេដបូក** ត្រូវបានបង្កើតឡើងដោយក្រុមការងាររេដបូកជាតិ ដើម្បី (១)បង្កើនការយល់ដឹងអំពីយេនឌ័រ និងទស្សនទាននៃការពង្រឹងភាពអង់អាចរបស់ស្ត្រី និងបញ្ហានានា ក្នុងចំណោមសមាជិកក្រុមការងាររេដបូកជាតិ ក្រុមប្រឹក្សាយោបល់រេដបូក និងក្រុមបច្ចេកទេសរេដបូក (២)ផ្តល់យោបល់អំពីការគិតគូរបញ្ហាយេនឌ័រទៅក្នុងសមាសភាគនៃយុទ្ធសាស្ត្ររេដបូកជាតិ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តជាបន្តបន្ទាប់ នៅពេលមានការរៀបចំឡើង និង (៣) តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរេដបូកដើម្បីធានាថា បញ្ហាយេនឌ័រត្រូវបានបញ្ចូល និងទទួលបានការដោះស្រាយសមរម្យ។ ក្រុមយេនឌ័ររេដបូក មានសមាជិកចំនួនបួនរូបមកពីស្ថាប័នរាជរដ្ឋាភិបាលចំនួនបួនគឺ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារី។

### ៦.៣.២ ការរៀបចំរចនាសម្ព័ន្ធសម្រាប់តាមដានត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

ការរៀបចំរចនាសម្ព័ន្ធសម្រាប់តាមដានត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវអនុលោមតាមគោលការណ៍ អភិបាលកិច្ចល្អ សុច្ចរិតភាព ការធានាឲ្យមានការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពពីអ្នកពាក់ព័ន្ធទាំងអស់ មានប្រសិទ្ធភាពនៃថ្លៃចំណាយនៅក្នុងការសម្រេចទិសដៅយុទ្ធសាស្ត្រ និងមានគណនេយ្យភាពក្នុងការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។ នៅក្នុងដំណាក់កាលអន្តរកាល ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ រចនាសម្ព័ន្ធដែលមានស្រាប់ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធច្រើនស្ថាប័នដូចជា ក្រុមការងាររេដបូកជាតិ និងលេខាធិការដ្ឋានរេដបូក ក្រុមបច្ចេកទេស ក្រុមប្រឹក្សាយោបល់រេដបូក និងក្រុមយេនឌ័ររេដបូក នឹងបន្តប្រតិបត្តិការជាធម្មតា។

<u>ក្រុមការងាររេដបូកជាតិ</u>

ក្រុមការងាររេដបូកជាតិ និងលេខាធិការដ្ឋានរេដបូក នឹងត្រូវធ្វើបច្ចុប្បន្នភាពដោយសេចក្តីសម្រេចរបស់រដ្ឋាភិបាល និងត្រូវមានគណនេយ្យភាព និងត្រូវរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច តាមរយៈក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) ។ ក្រុមការងាររេដបូកជាតិ បង្កើតឡើងក្នុងបំណងដូចតទៅៈ

- អភិបាលកិច្ច និងសម្របសម្រួលសកម្មភាពរេដបូកទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ
- តាមដានត្រួតពិនិត្យ និងបង្កើនការកែលម្អអភិបាលកិច្ចធនធានព្រៃឈើ ដើម្បីកាត់បន្ថយអត្រានៃការបាត់បង់ និងការរេចរិលព្រៃឈើ
- ធានាឲ្យមានប្រសិទ្ធភាព និងសមភាពនៃសេវាកម្មមូលនិធិ និងបែងចែកការលើកទឹកចិត្តដល់ស្ថាប័ននានាដែលអនុវត្តគោលនយោបាយ និងវិធានការរេដបូកឲ្យបានត្រឹមត្រូវ ។

<u>មុខងាររបស់ក្រុមការងាររេដបូកជាតិ</u>

ក្រុមការងាររេដបូកជាតិ ត្រូវមានអាណត្តិក្នុងការបំពេញមុខងារជាយុទ្ធសាស្ត្រនៅក្នុងក្របខណ្ឌនៃការសម្របសម្រួលតម្រង់ទិសលើដំណើរការអនុវត្ត និងការសម្របសម្រួលយន្តការដែលមានស្រាប់នៅក្នុងចំណោមក្រសួង និងស្ថាប័នដែលពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។ លើសពីនេះទៀត ក្រុមការងាររេដបូកជាតិ ដោយមានការគាំទ្រពីលេខាធិការដ្ឋានរេដបូក នឹងត្រូវបានរៀបចំឡើងក្នុងយន្តការជាតិដើម្បី

- ជួយសម្របសម្រួលការរៀបចំក្របខណ្ឌច្បាប់សម្រាប់ការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផល ពីការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ
- ជម្រុញ និងសម្របសម្រួល ការកែលម្អអភិបាលកិច្ចការងារប្រើប្រាស់ដី ឲ្យបានប្រសើរឡើង
- សម្របសម្រួលការកសាងសមត្ថភាព ដើម្បីធានាឲ្យមានការលើកទឹកចិត្ត ដល់អ្នកពាក់ព័ន្ធប្រកបដោយភាពត្រឹមត្រូវ និងសមធម៌
- សម្របសម្រួលការរៀបចំបង្កើតទីភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក ដើម្បីធ្វើនិយ័តកម្មលើវិធាននានា ដែលទាក់ទងនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការទូទាត់ផ្អែកលើលទ្ធផល ការគ្រប់គ្រង និងការផ្ទេរហិរញ្ញវត្ថុរេដបូក ក៏ដូចជាការវិភាជន៍ថវិកាលើកទឹកចិត្ត នៅថ្នាក់រដ្ឋបាលខុសៗគ្នាផងដែរ

DRAFT

- សម្របសម្រួលការបង្កើតទីភ្នាក់ងារជាតិសម្រាប់ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដើម្បីគ្រប់គ្រងការបំពេញមុខងារនៃប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងកម្រិតយោងព្រៃឈើ និងធ្វើនិយ័តកម្មលើវិធានការរេដបូកនានា
- សម្របសម្រួលការរៀបចំក្របខណ្ឌ និងប្រព័ន្ធព័ត៌មានសម្រាប់ការអនុវត្តប្រព័ន្ធធានាសុវត្ថិភាពរេដបូក ការបង្កើតគណៈកម្មាធិការប្រព័ន្ធធានាសុវត្ថិភាពរេដបូក ក៏ដូចជាការធ្វើនិយ័តកម្ម និងសម្របសម្រួលការអនុវត្តប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូករួមទាំងប្រព័ន្ធធានាសុវត្ថិភាពរេដបូក សវនកម្មហិរញ្ញវត្ថុ អន្តរកម្មសង្គម និងបរិស្ថាន។

ក្រុមការងាររេដបូកជាតិ និងលេខាធិការដ្ឋានរេដបូក ត្រូវធានានូវប្រសិទ្ធិភាពនៃការសម្របសម្រួលរវាងក្រសួង និងស្ថាប័នរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ សម្របសម្រួលគៀរគរធនធាន និងរិះរកវិធីសាស្ត្រ ដើម្បីដោះស្រាយឧបសគ្គនានាដែលតែងតែកើតមានឡើង នៅក្នុង ឬ អន្តរក្រសួង/អង្គភាព ដែលមានដែនសមត្ថកិច្ចផ្សេងៗគ្នា។ កិច្ចការនេះអាចសម្រេចបានតាមរយៈ៖

- ការសម្របសម្រួល និងការបន្សុីគោលនយោបាយ និងកម្មវិធីនានា ក្នុងចំណោមស្ថាប័ន និងវិស័យនានារបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ ជាពិសេសទាក់ទងនឹងការរៀបចំផែនការរូបវន្ត និងការអនុញ្ញាតឲ្យប្រើប្រាស់ដី
- ការរៀបចំផែនការ និងការសម្របសម្រួលលើការពង្រឹងការអនុវត្តច្បាប់ដើម្បីការពារដីព្រៃ ជាពិសេស ការកាប់ឈើ ការប្រើប្រាស់ដី និងការរានឆ្ការដីព្រៃខុសច្បាប់
- ការសម្របសម្រួលយុទ្ធសាស្ត្រទំនាក់ទំនង និងការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេសដោយ
    - បង្កើត និងអនុវត្តប្រព័ន្ធទំនាក់ទំនងដែលមានប្រសិទ្ធភាព ដើម្បីលើកកំពស់ការប្រាស្រ័យទាក់ទងការងារដែលផ្តល់លទ្ធផល ជាមួយអ្នកពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ
    - សម្របសម្រួលលើការរៀបចំជំហររបស់កម្ពុជាស្តីពីរេដបូក ក្នុងការត្រៀមរៀបចំចូលរួមពិភាក្សានៅក្នុងវេទិកាអន្តរជាតិនានា រួមទាំងការរក្សាទំនាក់ទំនង និងការប្រាស្រ័យទាក់ទងបានល្អ ក៏ដូចជាការចូលរួមនៅក្នុងការចរចាជាមួយអន្តរជាតិ។

## ៧. ធនធានហិរញ្ញវត្ថុ

ការទូទាត់ផ្អែកលើលទ្ធផល សំដៅលើការបង់ថ្លៃទៅឲ្យប្រទេសណាមួយ សម្រាប់ការអនុវត្តសកម្មភាពកាត់បន្ថយការបំភាយកាបូនពីព្រៃឈើ ឬ ការស្រូបយកកាបូនដោយព្រៃឈើពីបរិយាកាសបានដោយជោគជ័យ ដែលត្រូវបានផ្ទៀងផ្ទាត់ស្របតាមដំណើរការនៅក្រោមអនុសញ្ញា UNFCCC ធៀបនឹងកម្រិតយោងព្រៃឈើ ហើយលទ្ធផលនៃការកាត់បន្ថយការបំភាយ ឬ ការស្រូបយកកាបូននេះ បានអនុវត្តទៅតាមគោលនយោបាយ និងវិធានការរេដបូក ដែលមានការគោរព និងដោះស្រាយឆ្លើយតបនឹងប្រព័ន្ធធានាសុវត្ថិភាពរេដបូកសង្គម និងបរិស្ថាន។ ការរួមបញ្ចូលគ្នារវាងទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រនានា ដែលបានរៀបរាប់នៅក្នុងជំពូកខាងលើ ចាំបាច់ត្រូវតែសម្រេចឲ្យបាន ដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផល ពីការអនុវត្តយុទ្ធសាស្ត្ររេដបូក។



DRAFT

## ៧.១ ប្រភពហិរញ្ញប្បទាន

ក្នុងដំណាក់កាលដំបូង នៃការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ រាជរដ្ឋាភិបាលនឹងដាក់អាទិភាពលើការវិនិយោគមូលនិធិជាមុន (Non Results Based) ដែលមានការគាំទ្រពីថវិកាជាតិ ដៃគូអភិវឌ្ឍន៍ មូលនិធិទ្វេភាគី ពហុភាគី និងវិស័យឯកជន។ ដំណាក់កាលនេះនឹងជួយដល់រាជរដ្ឋាភិបាល ក្នុងការរួមបញ្ចូលគ្នានូវដំណើរការត្រៀមអនុវត្តរេដបូក និងអន្តរកាលនៃការអនុវត្តរេដបូក។ រាជរដ្ឋាភិបាលកម្ពុជានឹងពិចារណាផងដែរនូវឱកាសហិរញ្ញវត្ថុដែលផ្អែកលើទីផ្សារកាបូន (Market Based Mechanism)។ ការពិនិត្យឡើងវិញលើប្រភពហិរញ្ញប្បទាន នឹងត្រូវធ្វើឡើងនៅឆ្នាំ២០២០ ដើម្បីកំណត់ និងផ្តល់ពេលវេលាជាក់លាក់សម្រាប់ការទូទាត់ផ្អែកលើលទ្ធផលនៅដំណាក់កាលពីឆ្នាំ២០២១-២០២៥។ យោងតាមសេចក្តីត្រូវការចាំបាច់ យន្តការមួយនឹងត្រូវបង្កើតឡើង ដើម្បីគ្រប់គ្រងហិរញ្ញប្បទាន ដែលមានវិធីសាស្ត្រចាត់ចែងផ្សេងគ្នាទៅតាមលក្ខខណ្ឌរបស់ដៃគូអភិវឌ្ឍន៍ ដែលមានគោលការណ៍អាចទទួលយកបានទាំងជាតិ និងអន្តរជាតិ។

## ៧.២ អភិក្រមផ្អែកលើមូលនិធិ ( Fund Based Approach )

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះ ទោះបីកម្ពុជា បានធ្វើឲ្យមានការរីកចម្រើនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ដោយ ឧបសគ្គជាច្រើនខាងសមត្ថភាពនៅតែបន្តមាននៅឡើយ រួមផ្សំជាមួយនឹងភាពស្មុគស្មាញនៃរេដបូក និងភាពមិនទាន់ច្បាស់លាស់នៃការទូទាត់ផ្អែកលើលទ្ធផល។ ដូច្នេះ ប្រសិនបើការទូទាត់ផ្អែកលើលទ្ធផល ស្ថិតក្រោមការគ្រប់គ្រងដែលប្រើប្រាស់ត្រឹមតែប្រព័ន្ធជាតិ អាចនាំឲ្យលទ្ធផលដែលទទួលបាន មានកម្រិតទាបជាងការរំពឹងទុក។ លទ្ធផលនៃការសិក្សា ដែលបានធ្វើឡើងដោយក្រុមការងាររេដបូកជាតិ បានផ្តល់អនុសាសន៍ថា នៅក្នុងដំណាក់កាលដំបូង ជាបណ្តោះអាសន្ន ត្រូវប្រើប្រាស់វិធីសាស្ត្រ ឬ អភិក្រមដែលផ្អែកលើមូលនិធិ ដើម្បីគ្រប់គ្រងការទូទាត់ផ្អែកលើលទ្ធផលសម្រាប់រេដបូក ហើយដំណាក់កាលទីពីរជាបន្ត នឹងត្រូវពឹងផ្អែកកាន់តែច្រើនលើប្រព័ន្ធជាតិ បន្ទាប់ពីដំណាក់កាលអន្តរកាលបានបញ្ចប់។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់វិធីសាស្ត្រដែលផ្អែកលើមូលនិធិ ពុំមានន័យថា ស្ថិតនៅដាច់ដោយឡែកពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ជាតិស្រុងនោះឡើយ។ ផ្ទុយទៅវិញ វិធីនេះគួរតែផ្អែកលើ សមាសភាគនានា ដែលបានបង្ហាញលទ្ធផលវិជ្ជមានរួចទៅហើយ។ នៅក្នុងដំណាក់កាលដំបូង អាចប្រើប្រាស់ប្រព័ន្ធគណនីរបស់ជាតិ ដើម្បីរាយការណ៍អំពីទិន្នន័យនានា ដែលអាចឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្រង់យកទិន្នន័យនេះសម្រាប់ការរៀបចំផែនការមេ ការគ្រោងថវិកា និងការរៀបចំរបាយការណ៍។

## ៧.៣ គោលការណ៍

ភ្នាក់ងារគ្រប់គ្រងមូលនិធិរេដបូកជាតិដែលបានស្នើបង្កើតឡើង ត្រូវធ្វើការគ្រប់គ្រងចាត់ចែងទៅតាមគោលការណ៍ដូចតទៅ៖

- **ប្រសិទ្ធភាព៖** ប្រើប្រាស់សម្រាប់កាត់បន្ថយការបំភាយជាអតិបរមា តាមតែអាចធ្វើបាន
- **ប្រសិទ្ធផល៖** រួមចំណែកកាត់បន្ថយការបំភាយ តាមរបៀបដែលអាចកាត់បន្ថយថ្លៃចំណាយឲ្យនៅទាប
- **សមធម៌៖** ការបែងចែកមូលនិធិត្រូវធ្វើឡើងឲ្យបានត្រឹមត្រូវ និងមានសមធម៌ ជាពិសេស សម្រាប់ជាប្រយោជន៍ដល់ក្រុមដែលងាយរងគ្រោះ ដូចជា ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងស្ត្រី
- **ភាពគ្រប់គ្រាន់៖** ការផ្ទេរមូលនិធិ គួរតែធ្វើឡើងនៅពេលត្រូវការចាំបាច់ ដើម្បីធានាថា លំហូរនៃផលចំណូល កើតមានស្របគ្នាជាមួយតម្រូវការចំណាយ សម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

- **ភាពបត់បែនបាន៖** មូលនិធិ គួរតែប្រើប្រាស់គាំទ្រដល់សកម្មភាពខុសៗគ្នា ដែលរួមចំណែកដល់ការបង្កើនសន្និធិកាបូនព្រៃឈើ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កែលម្អការគ្រប់គ្រងជីវចម្រុះឲ្យកាន់តែប្រសើរឡើង ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ហើយទន្ទឹមនឹងនេះត្រូវមានលក្ខណៈសមស្របទៅនឹងលក្ខខណ្ឌសង្គម សេដ្ឋកិច្ច និងវប្បធម៌តាមទីកន្លែងនីមួយៗ និងមានភាពជាម្ចាស់លើព្រៃឈើ ព្រមទាំងសិទ្ធិប្រើប្រាស់ដីព្រៃច្រើនប្រភេទផងដែរ
- **តម្លាភាព៖** ការគ្រប់គ្រងមូលនិធិ គួរតែស្ថិតនៅក្រោមអង្គភាពកណ្តាលមួយនៅថ្នាក់ជាតិ ដើម្បីងាយស្រួលបូកសរុបការចំណាយ និងភស្តុភានានា។ ការកំណត់ពីគោលនយោបាយ និងវិធានការរេដបូក ដែលត្រូវទទួលបានការគាំទ្រ ត្រូវតែធ្វើឡើងតាមរយៈការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅមូលដ្ឋាន រួមទាំងសហគមន៍ ក្រុមស្ត្រី និងជនជាតិដើមភាគតិចផងដែរ។

## ៧.៤ ការបង្កើតភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក

ដើម្បីចាត់ចែងគ្រប់គ្រងអភិក្រមផ្អែកលើមូលនិធិ សម្រាប់ការទូទាត់ផ្អែកលើលទ្ធផល ក្រុមការងាររេដបូកជាតិនឹងសម្របសម្រួលការបង្កើតភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក។ ភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក ត្រូវធ្វើទំនាក់ទំនងជាមួយប្រភពធនធានដែលមានសក្តានុពល និងអ្នកប្រើប្រាស់ខុសៗគ្នា ហើយត្រូវគ្រប់គ្រងរួមគ្នាជាមួយអ្នកពាក់ព័ន្ធនានា និងមានគោលបំណងដូចតទៅ៖

- ផ្តល់នូវតម្លាភាព និងគណនេយ្យភាព លើការកៀរគធនធាន និងយន្តការផ្ទេរថវិកា
- សម្របសម្រួលការបែងចែកមូលនិធិប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ ធានាឲ្យមានការបែងចែកមូលនិធិត្រឹមត្រូវ តាមការអនុវត្តគោលនយោបាយ និងវិធានការរេដបូក
- ធានាឲ្យមានការគោរពតាមទិដ្ឋភាពសំខាន់ទាំងបីនៃប្រព័ន្ធធានាសុវត្ថិភាពរេដបូកគឺ សុចរិតភាព សង្គម បរិស្ថាន និងការជឿជាក់។

<u>តួនាទីរបស់ភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក</u>

ដើម្បីប្រតិបត្តិការឲ្យមានប្រសិទ្ធភាព ភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក ត្រូវមានតួនាទីដូចតទៅ៖

- គ្រប់គ្រងមូលនិធិរេដបូកដោយស្វ័យភាព ប្រកបដោយវិជ្ជាជីវៈ និងអាចជឿទុកចិត្តបាន ដោយផ្អែកលើប្រព័ន្ធដែលមានសុវត្ថិភាព និងបទដ្ឋានគណនេយ្យ ហើយអាចទុកចិត្តបានទាំងនៅកម្រិតជាតិ និងអន្តរជាតិ
- កៀរគមូលនិធិពីប្រភពនានា ដូចជាពីវិស័យសាធារណៈ និងឯកជន តាមរយៈសកម្មភាពស្វែងរកមូលនិធិជាប្រព័ន្ធ ផ្អែកលើកម្មវិធី និងប្រកបដោយវិជ្ជាជីវៈ
- រៀបចំយន្តការផ្តល់មូលនិធិរួមមាន
    - គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ពិសេសផែនការសកម្មភាពរេដបូក
    - គាំទ្រដល់ការបំពេញមុខងារសម្របសម្រួលរបស់ក្រុមការងាររេដបូកជាតិ និងលេខាធិការដ្ឋានរេដបូក
    - ផ្តល់ទុនវិនិយោគគាំទ្រដល់ការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ដែលមានលក្ខខណ្ឌកំណត់ជាមុន ឬ គោលនយោបាយ និងវិធានការដទៃទៀត ដែលរួមចំណែកដល់កិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយការបំភាយ និង/ឬ សម្រួលដល់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ
    - ផ្តល់ការលើកទឹកចិត្តដល់ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងក្រុមអ្នកពាក់ព័ន្ធសម្រាប់កិច្ចប្រឹងប្រែងសម្រេចលទ្ធផលក្នុងការបង្កើតលក្ខខណ្ឌនានា ដែលជួយពង្រឹងដល់ការកាត់បន្ថយការ

បំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងតំបន់របស់ពួកគេ តាមរយៈការអនុវត្តគោលនយោបាយ និងវិធានការរេដបូក និងសកម្មភាពជាយុទ្ធសាស្ត្រ និង/ឬ ការបង្កើតគោលនយោបាយគាំទ្រចាំបាច់នានា

  - ○ គាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ដែលផ្តល់ប្រយោជន៍ផ្ទាល់ និងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

- ធានាឲ្យមានពិធីសារមួយដើម្បីធ្វើឲ្យប្រាកដថា ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ត្រូវបានអនុវត្តស្របទៅតាមការអនុម័តឯកភាពលើគោលនយោបាយ និងវិធានការរេដបូក
- ត្រូវធានាថាការអនុវត្តបំពេញតាមលក្ខខណ្ឌនៃប្រព័ន្ធធានាសុវត្ថិភាពរេដបូក មុនពេលសម្រេចផ្តល់មូលនិធិគាំទ្រដល់ការអនុវត្តទាំងនោះ ទោះបីជាបានរៀបចំលក្ខខណ្ឌសម្រាប់កសាងភាពជឿជាក់សង្គម ឬបរិស្ថានក៏ដោយ។

យន្តការគណនេយ្យភាពរបស់ភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក

ដើម្បីរក្សាទំនុកចិត្តលើភ្នាក់ងារជាតិគ្រប់គ្រងមូលនិធិរេដបូក យន្តការគណនេយ្យភាពមួយនឹងត្រូវដាក់ឲ្យអនុវត្តដើម្បីធានាតម្លាភាពជាអតិបរមានៃប្រតិបត្តិការរបស់ភ្នាក់ងារនោះ។ សវនកម្មហិរញ្ញវត្ថុឯករាជ្យនឹងត្រូវធ្វើឡើងជាប្រចាំទៅគោលការណ៍កំណត់។ របាយការណ៍ហិរញ្ញវត្ថុរបស់ភ្នាក់ងារគ្រប់គ្រងហិរញ្ញវត្ថុរេដបូក និងរបាយការណ៍សវនកម្មឯករាជ្យដែលបានរាយការណ៍ជូនដល់ក្រុមការងាររេដបូកជាតិនឹងត្រូវចុះផ្សព្វផ្សាយ និងមានលទ្ធភាពទទួលបានជាសាធារណៈ។ ក្រុមការងាររេដបូកជាតិនឹងបញ្ជូនរបាយការណ៍ទាំងនេះជូនប្រធានស្ថាប័នមានសមត្ថកិច្ច ដើម្បីធានាគណនេយ្យភាពចំពោះមូលនិធិនានា ដែលបានទទួលតាមរយៈថវិកាជាតិ និង/ឬ ជំនួយហិរញ្ញប្បទានដែលបានកត់ត្រាជាចំណូលរបស់រដ្ឋ។

## ៨. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការបង្កើត និងការបញ្ជ្រាបក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ (M&E) ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ គឺជាកិច្ចប្រឹងប្រែងរយៈពេលវែង ដែលមានការពាក់ព័ន្ធជាយុទ្ធសាស្ត្រ ដោយសារក្របខណ្ឌនេះនឹងបង្កើតឲ្យមានបរិយាកាសអំណោយផលល្អ ផ្អែកលើគណនេយ្យភាព និងការរៀនសូត្រ។ ការកែលម្អគណនេយ្យភាពនឹងសម្រួលដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុរេដបូកអន្តរជាតិថ្មីៗ ហើយការរៀនសូត្រពីការវិនិយោគនានា នឹងបង្កើតចំណេះដឹងថ្មីៗ ដែលមានសារៈសំខាន់សម្រាប់ការរៀបចំគោលនយោបាយទៅអនាគត ជាពិសេសគោលនយោបាយទាក់ទងនឹងវិស័យព្រៃឈើ។ ក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិមានគោលដៅ៖

- តាមដានត្រួតពិនិត្យ ការរួមវិភាគទានពីរេដបូក នៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយអភិវឌ្ឍន៍កាបូនទាបនៅកម្ពុជា
- បង្កើតភស្តុតាង និងមេរៀននានា ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយទៅអនាគត សម្រួលឲ្យមានសមាហរណកម្ម និងស៊ីចង្វាក់គ្នាក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្ររេដបូកជាតិនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ ជាពិសេសនៅក្នុងវិស័យនានាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- ផ្តល់ព័ត៌មានដែលចាំបាច់ សម្រាប់បំពេញកាតព្វកិច្ចរាយការណ៍ទៅអនុសញ្ញា UNFCCC និងដៃគូអភិវឌ្ឍន៍ ។

DRAFT

## ៨.១ គោលការណ៍

គោលការណ៍នៃក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្រវេដបូកជាតិរួមមាន៖

- **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីនានារបស់ជាតិ៖** ក្របខណ្ឌនេះត្រូវរួមបញ្ចូលគ្នា ជាមួយប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ជាតិ។ សូចនាករនានានិងនីតិវិធីតាមដាន នឹងពឹងផ្អែកលើទិន្នន័យដែលបច្ចុប្បន្ន កំពុងតាមដានត្រួតពិនិត្យដោយក្រសួងពាក់ព័ន្ធនានានៅក្នុងករណីសមស្រប។ នីតិវិធីទាំងនោះ ក៏មានលក្ខណៈស្របគ្នាជាមួយគោលការណ៍ណែនាំរបស់ក្រសួងផែនការសម្រាប់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ជាតិផងដែរ។ ក្របខណ្ឌនេះនឹងផ្អែកលើកិច្ចផ្តួចផ្តើមនានាដែលមានស្រាប់ សម្រាប់តាមដានត្រួតពិនិត្យ និងរាយការណ៍អំពីការបំភាយឧស្ម័នផ្ទះកញ្ចក់
- **ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព៖** ក្របខណ្ឌនេះ នឹងផ្តល់វិធីមួយ សម្រាប់ការវាស់វែងអំពីប្រសិទ្ធផល និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ដើម្បីសម្រេចបានចំណុចគោលដៅគ្រោងទុកនៅក្នុងយុទ្ធសាស្ត្រវេដបូកជាតិ និងផែនការសកម្មភាពនៃយុទ្ធសាស្ត្រនេះ ដែលនឹងជួយកែលម្អគណនេយ្យភាពចំពោះសាធារណជន ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយអន្តរជាតិឲ្យកាន់តែប្រសើរឡើង
- **ការលើកកម្ពស់ការចូលរួមរៀនសូត្រ៖** ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រវេដបូកជាតិ គឺជាកិច្ចខិតខំប្រឹងប្រែងថ្មីមួយនៅកម្ពុជា និងនៅអន្តរជាតិ។ ការបង្កើតឲ្យមានមូលដ្ឋានភស្តុតាងរឹងមាំ ដែលបញ្ជាក់ថាយុទ្ធសាស្ត្រមានប្រសិទ្ធភាព មានសារៈសំខាន់ជាសារវន្ត ក្នុងការផ្តល់ព័ត៌មានដល់អ្នករៀបចំគោលនយោបាយទៅអនាគត។ ដូច្នេះក្របខណ្ឌនេះ ផ្តោតលើការបង្កើតចំណេះដឹង តាមរយៈវិធីសាស្ត្រនៃការចូលរួម និងគាំទ្រដល់ការកំណត់ និងការចែករំលែកមេរៀនដែលទទួលបាន
- **ការដោះស្រាយបញ្ហាយេនឌ័រ៖** ស្ត្រី និងក្រុមជនងាយរងគ្រោះ ច្រើនតែស្ថិតក្នុងចំណោមអ្នកដែលរងឥទ្ធិពលធ្ងន់ធ្ងរជាងគេ ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះនឹងរួមចំណែកក្នុងការដោះស្រាយសមភាពយេនឌ័រ ការគិតគូរអំពីយេនឌ័រនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រទៅក្នុងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសក្នុងវិស័យព្រៃឈើ។

## ៨.២ អនុក្រម

ក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រវេដបូកជាតិ ត្រូវរៀបចំឡើង ដោយដកស្រង់យកនូវមេរៀន និងបទពិសោធន៍ដែលល្អប្រសើបំផុតជាលក្ខណៈអន្តរជាតិ។ កម្ពុជារៀបចំឯកសារទស្សនទាន ដើម្បីកំណត់តម្រូវការបរិមាណ និងកៀរគរធនធាន ទៅតាមសេចក្តីត្រូវការចាំបាច់ សម្រាប់ការចាប់ផ្តើមរៀបចំក្របខណ្ឌការងារនេះឲ្យបានឆាប់រហ័ស។ ក្របខណ្ឌនេះត្រូវរៀបចំឲ្យបានរួចរាល់នៅឆ្នាំ២០១៧ ដោយរួមបញ្ចូលទាំង ទ្រឹស្តីអំពីការផ្លាស់ប្តូរ (Theory of Change) ក្របខណ្ឌលទ្ធផលដោយមានទិន្នន័យគោល និងចំណុចដៅច្បាស់លាស់សម្រាប់ឃ្លាំមើលការអនុវត្តយុទ្ធសាស្ត្រវេដបូកជាតិ និងផែនការសកម្មភាពនៃយុទ្ធសាស្ត្រនេះ រួមទាំងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ គោលការណ៍ណែនាំសម្រាប់ការវិភាគ និងការធ្វើរបាយការណ៍ គោលការណ៍ណែនាំសម្រាប់ការចងក្រង និងចែករំលែកចំណេះដឹង ការរៀនសូត្រ និងការចែករំលែកលទ្ធផល គោលការណ៍ណែនាំសម្រាប់ការធ្វើសមាហរណកម្មនៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងការចាត់ចែងពិស្តារខាងស្ថាប័ន និងយន្តការសម្របសម្រួល។ ផែនការដែលចែងអំពីគោលនយោបាយ និងវិធានការវេដបូក ការអភិវឌ្ឍសមត្ថភាព និងការកំណត់ថ្លៃចំណាយសម្រាប់ការអនុវត្តរយៈពេលវែង ព្រមទាំងការបញ្ជ្រាបក្របខណ្ឌនេះ នៅក្នុងក្រសួងពាក់ព័ន្ធ ក៏នឹងត្រូវរៀបចំឡើងផងដែរ។

នៅក្នុងរយៈពេលមធ្យម (ឆ្នាំ២០១៧-២០២០) ក្របខណ្ឌនេះនឹងត្រូវដាក់ឲ្យប្រតិបត្តិការនៅតាមវិស័យនានា ពីសំណាក់ក្រសួងពាក់ព័ន្ធ ហើយសកម្មភាពជាអាទិភាព ក៏នឹងត្រូវជ្រើសរើសផងដែរ អាស្រ័យទៅតាមសមត្ថភាព និងធនធានដែលមាន។ ការរួមបញ្ចូលក្របខណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ទៅក្នុងការរៀបចំផែនការនៅមូលដ្ឋាន ក៏នឹងត្រូវអនុវត្តសាកល្បងផងដែរ។ ធនធាននឹងត្រូវផ្តល់ឲ្យបានគ្រប់គ្រាន់នៅក្នុងដំណាក់កាលដំបូង សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយ និងវិធានការរេដបូកជ្រើសរើសមួយចំនួន ដើម្បីបំពេញថ្លៃចំណាយបន្ថែម សម្រាប់អភិវឌ្ឍសមត្ថភាពបច្ចេកទេសជំនាញអំពីក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្ររេដបូកជាតិ ការប្រមូលទិន្នន័យគោល និងការបង្កើតទ្រឹស្តីអំពីការផ្លាស់ប្តូរ ការរៀនសូត្រ ការចងក្រង និងចែករំលែកចំណេះដឹង។ នៅក្នុងរយៈពេលវែង (ក្រោយឆ្នាំ ២០២១) ក្របខណ្ឌនេះនឹងត្រូវកែសម្រួល ដោយផ្អែកតាមមេរៀនដែលទទួលបាន និងបញ្ជ្រាបទៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ។

## ៨.៣ ការគ្រប់គ្រង និងការចាត់ចែងរចនាសម្ព័ន្ធសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

លេខាធិការដ្ឋានរេដបូក សម្របសម្រួលរៀបចំ និងអនុវត្តក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្ររេដបូកជាតិ។ លេខាធិការដ្ឋាននេះ ក៏មានភារកិច្ចទទួលខុសត្រូវលើការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិផងដែរ។ ជាងនេះទៀត លេខាធិការដ្ឋានរេដបូក សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ធ្វើការពិនិត្យលើវឌ្ឍនភាពប្រចាំឆ្នាំ ការអនុវត្តគោលនយោបាយតាមវិស័យពាក់ព័ន្ធ និងគោលនយោបាយជាតិ ដូចជា កម្មវិធីព្រៃឈើជាតិ។ អង្គភាពមួយដែលទទួលបន្ទុកគ្រប់គ្រង និងអនុវត្តក្របខណ្ឌការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ នឹងត្រូវរៀបចំឡើងនៅក្នុងលេខាធិការដ្ឋានរេដបូក ដើម្បីសម្របសម្រួលការផ្លាស់ប្តូរទិន្នន័យ និងការបញ្ជ្រាបក្របខណ្ឌការងារនេះ ទៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ។ សូចនាករ នីតិវិធី និងការទទួលខុសត្រូវលើការប្រមូលទិន្នន័យ នឹងត្រូវបានឯកភាពគ្នាជាមួយក្រសួងពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងភាគីដទៃទៀត ដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនេះ។ សម្រាប់ការតាមដានរយៈពេលវែង ការកសាងភាពជាដៃគូជាមួយគ្រឹះស្ថានសិក្សាស្រាវជ្រាវ សម្រាប់គ្រប់គ្រងបណ្តាញការងារនៅនឹងកន្លែង ក៏នឹងត្រូវបានសិក្សាផងដែរ។ រចនាសម្ព័ន្ធនេះ ក៏នឹងត្រូវយកមកប្រើប្រាស់ផងដែរសម្រាប់សិក្សាវាយតម្លៃ អំពីប្រសិទ្ធភាពនៃយុទ្ធសាស្ត្ររេដបូកជាតិ ដោយផ្អែកលើទិន្នន័យដែល បណ្តាញនេះប្រមូលបាន។

DRAFT

# ៩. សេចក្តីសន្និដ្ឋាន

យុទ្ធសាស្ត្ររេដបូកជាតិ ទទួលស្គាល់ថា ការអនុវត្តគោលនយោបាយ និងវិធានការរេដបូក ដោយជោគជ័យ ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ និងការរេចរិលព្រៃឈើ រួមចំណែកដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការអភិរក្ស និងការពង្រីកសន្និធិកាបូនព្រៃឈើ អាស្រ័យលើការប្តេជ្ញាខ្ពស់ក្នុងការផ្លាស់ប្តូររបៀបនៃការអនុវត្តសកម្មភាពសំខាន់ៗជាបន្តបន្ទាប់ ដែលនាំឈានទៅដល់ការធ្វើកំណែទម្រង់លើរបៀបធ្វើការតាមទម្លាប់ចាស់ នៅក្នុងការគ្រប់គ្រង និងអភិបាលកិច្ចការប្រើប្រាស់ដីនៅកម្ពុជា។ ដោយពិចារណាអំពីកាលៈទេសៈ និងអធិបតេយ្យភាពរបស់ជាតិ ការផ្លាស់ប្តូរវិធីសាស្ត្រគ្រប់គ្រងវិស័យព្រៃឈើនៅកម្ពុជា អាចធ្វើទៅបានតែតាមរយៈនៃការបង្កើតឲ្យមានគំរូគ្រប់គ្រងថ្មីៗ និងការបង្កើត ឬ ពង្រឹងស្ថាប័នបទប្បញ្ញត្តិ យន្តការ ទំនាក់ទំនងអន្តរក្រសួង និងប្រព័ន្ធអភិបាលកិច្ច។

ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរកំពូលនេះ ប្រការសំខាន់បំផុតត្រូវធានាថា នីតិវិធីនានាត្រូវតែមានតម្លាភាព ប្រព័ន្ធដែលផ្តល់លក្ខខណ្ឌអំណោយផល ត្រូវតែបានពង្រឹងកែលម្អឲ្យបានកាន់តែប្រសើរឡើង ដើម្បីធានាឲ្យមានគណនេយ្យភាពសាធារណៈ ទិន្នន័យ និងផែនទីត្រូវតែបានធ្វើសមាហរណកម្ម ការសម្របសម្រួលអន្តរវិស័យនានដោយប្រសិទ្ធភាព សមធម៌ និងដែលមានឥទ្ធិពលត្រូវតែអនុវត្តឲ្យបាន ក្នុងចំណោមស្ថាប័នរដ្ឋាភិបាល នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល។ កំណែទម្រង់ទាំង

នេះ  ទាមទារនូវការប្តេជ្ញាយ៉ាងមុតមាំចំពោះផលប្រយោជន៍សាធារណៈ  ការបើកទូលាយចំពោះការគិតគូរដោះស្រាយបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រ និងរេដបូក ហើយប្រការសំខាន់ជាងនេះទៀតគឺ ការយល់ដឹង និងចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធនានាក្នុងការឆ្លើយតបលើផ្នែកទទួលខុសត្រូវរបស់ខ្លួន ដើម្បីជម្រុញលើកទឹកចិត្ត ក៏ដូចជាការចូលរួមក្នុងដំណើរការពង្រីកការផ្លាស់ប្តូរលទ្ធផលប្រកបដោយជោគជ័យ ទៅរកលំនាំនៃការអភិវឌ្ឍដោយចីរភាព តាមរយៈការលើកកំពស់ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសមាហរណកម្មអន្តរវិស័យ  និងគោលនយោបាយពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់  និងការគ្រប់គ្រងធនធានព្រៃឈើ ធនធានធម្មជាតិ និងដី និងការកាត់បន្ថយការបាត់បង់ និងការរេចរិលព្រៃឈើ។ នេះជាគោលដៅចុងក្រោយនៃយុទ្ធសាស្ត្ររេដបូកជាតិ។

DRAFT